រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៣

អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

ស៊ុយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៧១៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

ចំពោះ

លោកជំទាវ ខួន ឆួន

ដែលមានស្នាដៃល្អ និងមានគុណបំណាច់យ៉ាងធំធេង
ក្នុងការចូលរួមចំណែកកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៣ស.១៣០៦.៧២ ៦

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៣

ព្រះ: ... ស.ណ
សំណៅចម្លងត្រឹមត្រូវតាមច្បាប់ដើមសម្រាប់ការចែកផ្សាយ
រាជធានីភ្នំពេញ ... ឆ្នាំ២០១៣
... រាជរដ្ឋាភិបាល

សយ សុខា

p

ព្រះរាជក្រឹត្យ

នស/រកត/០៦១៣/៧១៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

ចំពោះ

ឯកឧត្តម ឈួន ចាន់ថា

ដែលមានស្នាដៃល្អ និងមានគុណបំណាច់យ៉ាងធំធេង
ក្នុងការចូលរួមចំណែកកសាង និងអភិវឌ្ឍន៍ប្រទេសជាតិ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៦ល. ១៣០៦. ៧២៧

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៣

លេខៈ ៧[illegible] ស.ណ
សំណៅដែលអានផ្ទៀងផ្ទាត់ជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែកក្កដា ឆ្នាំ២០១៣
[illegible]រាជរដ្ឋាភិបាល

សយ សុខា

ព្រះរាជក្រឹត្យ

យើង

នស/រកត/០៦១៣/៧១៤

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃការបោះឆ្នោតជ្រើសរើស ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា នីតិកាលទី៣ នាសម័យប្រជុំដំបូង នៅថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១២
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំង ជាទីប្រឹក្សាអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សម្រាប់នីតិកាលទី៣ មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន :

- ឯកឧត្តមបណ្ឌិត ជាឡាល់ អាល់ អាស្វាដ JALAL AL ASWAD
- ឯកឧត្តម ហ្វាវាដ អាល់ អាស្វាដ FAWAZ AL ASWAD

មាត្រា ២ : សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ពាសស.១៣០៦.៧២៨

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០១៣

លេខ [illegible]២៤ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែកក្កដា ឆ្នាំ២០១៣
[illegible]រាជរដ្ឋាភិបាល
សយ សុខា

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៤៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីសរុបទំហំ ១៧.៨៧៧ ហិកតា នៅឃុំជូនបា ស្រុកគាស់ក្រឡ និងឃុំកន្ទឺ ១ ស្រុកបាណន់ ខេត្តបាត់ដំបង ក្នុងនោះ កាត់ចេញពីដីតំបន់ព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ និងកាត់ចេញពីដីសម្បទានព្រៃឬស្សីរបស់ក្រុមហ៊ុន តាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣.២៩៣ គ្រួសារ និងរក្សាទុកមួយចំណែក ជាដីសាធារណៈរបស់រដ្ឋ (ដីតំបន់)

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

p

- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ៧៣៩ ខបប ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា.១..

ត្រូវបានកាត់ផ្ទៃដីសរុបទំហំ ១៧.៨៧៧ ហិកតា ក្នុងនោះ (១) ទំហំ ១៧.៨១៨ ហិកតា កាត់ចេញពីដីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ និង (២) ទំហំ ៥៩ ហិកតា កាត់ចេញពីដីសម្បទានព្រៃឫស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មទំហំ ១៧.៣៦៦ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៥១១ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ (ដីភ្នំ) នៅភូមិសាស្ត្រ ដូចខាងក្រោម ៖

- កាត់ផ្ទៃដីសរុបទំហំ ១២.១៤៣ ហិកតា ក្នុងនោះ (១) ទំហំ ១២.០៨៤ ហិកតា កាត់ចេញពីដីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ និង (២) ទំហំ ៥៩ ហិកតា កាត់ចេញពីដីសម្បទានព្រៃឫស្សីរបស់ក្រុមហ៊ុន ភាពីម៉ិច និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មទំហំ ១១.៦៣២ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៥១១ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ (ដីភ្នំ) ភូមិគោករកា ឃុំដូនបា ស្រុកគាស់ក្រឡ
- កាត់ផ្ទៃដីទំហំ ៥.៧៣៤ ហិកតា ចេញពីដីគម្របព្រៃឈើបម្រុងទុកអចិន្ត្រៃយ៍ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ នៅភូមិថ្មី ឃុំកន្ទឺ ១ ស្រុក បាណន់

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

p

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ៣.២៩៣ គ្រួសារ នៅនៅភូមិសាស្ត្រដូចខាងក្រោម ៖

- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២.២៤៧ គ្រួសារ នៅភូមិគោករកា ឃុំដូនបា ស្រុកគាស់ក្រឡ
- ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១.០៤៦ គ្រួសារ នៅភូមិថ្មី ឃុំកន្ទឺ១ ស្រុកបាណន់ ។

មាត្រា ៣.-

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបាត់ដំបង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៤៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីសរុបទំហំ ២.២០៦,១២ ហិកតា នៅឃុំអូរបីជាន់ និងឃុំគូប ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ក្នុងនោះកាត់ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ កាត់ចេញពីដីគម្របព្រៃឈើដែលមានដីកាដកហូត និងកាត់ចេញពីដីស្ថានីយ៍ផ្សព្វផ្សាយ និងស្តារព្រៃឈើស្ទួលត្រគ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៥៦៨ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

p

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ៨២២ ខ.បជ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបន្ទាយមានជ័យ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១..

ត្រូវបានកាត់ផ្ទៃដីសរុបទំហំ **២.២០៦,១២** ហិកតា ក្នុងនោះ (១) ទំហំ ១.១១៧,៨០ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ (២) ទំហំ ៤០៩,៥៩ ហិកតា កាត់ចេញពីដីគម្របព្រៃឈើដែលមានដីកាដកហូតលេខ ១៩៦ លេខ ២០៣ និង២០៤ ដក.ខបជ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៦ និង (៣) ទំហំ **៦៧៨,៧៣** ហិកតា កាត់ចេញពីដីស្ថានីយ៍ផ្សព្វផ្សាយ និងស្តារព្រៃឈើស្នួលទ្រេត និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ១៦៣,២១ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ (ផ្លូវ, ប្រឡាយ, អូរ...) នៅស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ដែលស្ថិតក្នុងភូមិ ឃុំ ដូចខាងក្រោម ៖

- ផ្ទៃដីទំហំ ១៦,០១ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ សម្រាប់ធ្វើប្រទានកម្មទំហំ ១៥,៤៩ ហិកតា ជាកម្មសិទ្ធជូនប្រជាពលរដ្ឋ និងទំហំ ០,៥២ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិបន្ទាយថ្មី ឃុំអូរបីជាន់
- ផ្ទៃដីទំហំ ១១៣ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ សម្រាប់ធ្វើប្រទានកម្មទំហំ ១០៣,៣៦ ហិកតា ជាកម្មសិទ្ធជូនប្រជាពលរដ្ឋ និងទំហំ ៩,៦៤ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិអូរបីជាន់ ឃុំអូរបីជាន់

- ផ្ទៃដីទំហំ ៥៩៨,៨០ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ សម្រាប់ធ្វើប្រទានកម្មទំហំ ៥៥៥,៤១ ហិកតា ជាកម្មសិទ្ធជូនប្រជាពលរដ្ឋ និងទំហំ ៤៣,៣៩ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិប្រាសាទ ឃុំអូរបីជាន់
- កាត់ផ្ទៃដីសរុបទំហំ ៥៤៣,៨៦ ហិកតា ក្នុងនោះ (១) ទំហំ ១៨៥,២៨ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ និង (២) ទំហំ ៣៥៨,៥៨ ហិកតា កាត់ចេញពីដីស្ថានីយ៍ផ្សព្វផ្សាយ និងស្តារព្រៃឈើស្ទួលទ្រេត សម្រាប់ធ្វើប្រទានកម្មទំហំ ៤៩២,៥៧ ហិកតា ជាកម្មសិទ្ធជូនប្រជាពលរដ្ឋ និងទំហំ ៥១,២៩ ហិកតា ។រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិស្ទួលទ្រេត ឃុំអូរបីជាន់
- កាត់ផ្ទៃដីសរុបទំហំ ១២៩,៣២ ហិកតា ក្នុងនោះ (១) ទំហំ ២៣,៥០ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ (២) ទំហំ ១០៥,៨២ ហិកតា កាត់ចេញពីដីដែលមានដីកាដកហូតសម្រាប់ធ្វើប្រទានកម្មទំហំ ១២៤,៣៨ ហិកតា ជាកម្មសិទ្ធជូនប្រជាពលរដ្ឋ និងទំហំ ៤,៩៤ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិថ្មល់បត់ ឃុំអូរបីជាន់
- កាត់ផ្ទៃដីសរុបទំហំ ៤០៨,៣១ ហិកតា ក្នុងនោះ (១) ទំហំ ៥១,១៤ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ (២) ទំហំ ៣០៤,១៧ ហិកតា កាត់ចេញពីដីដែលមានដីកាដកហូត និង (៣) ទំហំ ៥៣ ហិកតា កាត់ចេញពីដីស្ថានីយ៍ផ្សព្វផ្សាយ និងស្តារព្រៃឈើស្ទួលទ្រេត សម្រាប់ធ្វើប្រទានកម្មទំហំ ៣៩៤,៧០ ហិកតាជាកម្មសិទ្ធជូនប្រជាពលរដ្ឋ និងទំហំ ១៣,៦១ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិយាងដង្កំ ឃុំអូរបីជាន់
- កាត់ផ្ទៃដីសរុបទំហំ ៣៩៦,៨២ ហិកតា ក្នុងនោះ (១) ទំហំ ១២៩,៦៧ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ និង (២) ទំហំ ២៦៧,១៥ ហិកតា កាត់ចេញពីដីស្ថានីយ៍ផ្សព្វផ្សាយ និងស្តារព្រៃឈើស្ទួលទ្រេត សម្រាប់ធ្វើប្រទានកម្មទំហំ ៣៥៧ ហិកតា ជាកម្មសិទ្ធជូនប្រជាពលរដ្ឋ និងទំហំ ៣៩,៨២ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិកូនត្រី ឃុំកូប

តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបន្ទាយមានជ័យ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង ចំនួន ៥៦៨ គ្រួសារ នៅស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ដែលស្ថិតក្នុងភូមិ ឃុំ ដូចខាងក្រោម ៖

- ប្រទានកម្មជាកម្មសិទ្ធជូនប្រជាពលរដ្ឋ ១៤ គ្រួសារ នៅភូមិបន្ទាយថ្មី ឃុំអូរបីជាន់
- ប្រទានកម្មជាកម្មសិទ្ធជូនប្រជាពលរដ្ឋ ១៨ គ្រួសារ នៅភូមិអូរបីជាន់ ឃុំអូរបីជាន់
- ប្រទានកម្មជាកម្មសិទ្ធជូនប្រជាពលរដ្ឋ ១៨៩ គ្រួសារ នៅភូមិប្រាសាទ ឃុំអូរបីជាន់

p

- ប្រទានកម្មជាកម្មសិទ្ធជូនប្រជាពលរដ្ឋ ១១២ គ្រួសារ នៅភូមិស្នួលទ្រេត ឃុំអូរបីជាន់
- ប្រទានកម្មជាកម្មសិទ្ធជូនប្រជាពលរដ្ឋ ១៩ គ្រួសារ នៅភូមិថ្នល់បត់ ឃុំអូរបីជាន់
- ប្រទានកម្មជាកម្មសិទ្ធជូនប្រជាពលរដ្ឋ ៧៦ គ្រួសារ នៅភូមិ យាងដង្គំ ឃុំអូរបីជាន់
- ប្រទានកម្មជាកម្មសិទ្ធជូនប្រជាពលរដ្ឋ ១៨០ គ្រួសារ នៅភូមិកូនត្រី ឃុំកូប ។

មាត្រា ៣..

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្តបន្ទាយមានជ័យ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

មាត្រា ៤ ..

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១១ ខែ មិថុនា ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣៤៧.អនក្រ.បក

អនុក្រឹត្យ
ស្ដីពី
ការកាត់ដីទំហំ ១៧៥,៧៨ ហិកតា នៅស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ចេញពីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ១៦២ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្ដីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្ដីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ

p

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៣/៦០៥ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៨៨អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ៣៧២អបខ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ដីទំហំ ១៧៥,៧៨ ហិកតា ចេញពីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៦១៣/៦០៥ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៣ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មដីទំហំ ១៦៩,៨១ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីទំហំ ៥,៩៧ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិព្រៃផ្តៅ ឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 84 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ១៦២គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិព្រៃផ្តៅ ឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ។

មាត្រា ៣.-

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

p

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
  អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣៤៩ អនក្រ.បក

អនុក្រឹត្យ
ស្តីពី

ការកាត់ដីទំហំ ៩១៩,៥៦ ហិកតា នៅស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ ចេញពីដីដែនជម្រកសត្វព្រៃបឹងពែរ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៥៤ គ្រួសារ និងរក្សាទុកមួយចំណែក សម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការផ្តល់សិទ្ធិលើក្បាលដី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

p

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៣/៦០១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ .
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ២៤២ សណ.កធ ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ធំ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១..

ត្រូវបានកាត់ដីទំហំ ៩១៩,៥៦ ហិកតា ចេញពីដីដែនជម្រកសត្វព្រៃបឹងពែរ ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៦១៣/៦០១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៣ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មទំហំ ៨៨៨,២៦ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៥៤ គ្រួសារ និងទំហំ ៣១,៣០ ហិកតា រក្សាទុកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅភូមិពាមអាទិត្យ ឃុំសាគ្រាម ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

មាត្រា ២..

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ធំ ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិពាមអាទិត្យ ឃុំសាគ្រាម ស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ ។

មាត្រា ៣..

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ៨៦១ក្បាលដី ជូនប្រជាពលរដ្ឋ ២៥៤ គ្រួសារ

p

មាត្រា ៤..

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ធំ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

មាត្រា ៥..

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៦..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៥០ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីទំហំ ១.៤៣០,០១ ហិកតា នៅស្រុកប្រាសាទបល្ល័ង្ក ខេត្តកំពង់ធំ កាត់ចេញពីដែនជម្រកសត្វព្រៃបឹងពែរ ដើម្បីធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៥៥ គ្រួសារ និងរក្សាទុកមួយចំណែកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការផ្តល់សិទ្ធិលើក្បាលដី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

p

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៣/៦០០ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិត២២០ ចុះថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ធំ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ដីទំហំ ១.៤៣០,០១ ហិកតា ចេញពីដែនជម្រកសត្វព្រៃបឹងពែរ ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៦១៣/៦០០ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៣ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្ម ទំហំ ១.៤០០,៨៦ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ២៩,១៥ ហិកតា រក្សាទុកសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៅភូមិអូរអង្គរ ឃុំសាគ្រាម ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ធំ ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិអូរអង្គរ ឃុំសាគ្រាម ស្រុកប្រាសាទបល្ល័ង្គ ខេត្តកំពង់ធំ ។

មាត្រា ៣.-

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុប ៧០៣ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ៧០០ ក្បាលដី ជូនប្រជាពលរដ្ឋ ៣៥៥ គ្រួសារ និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ០៣ ក្បាលដី (ដីទួលកប់ខ្មោច១ ,ដីទួលអ្នកតា ១ និង ដីសាលារៀន១) ។

p

មាត្រា ៤.-

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ធំ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

មាត្រា ៥.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៦.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣៥១ អនក្រ.បក

អនុក្រឹត្យ
ស្តីពី

ការកាត់ដីសរុបទំហំ ១.០៦៦,៩២ ហិកតា នៅស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ក្នុងនោះ កាត់ចេញពី (១) ដីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ (២) ដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន HLH Agriculture និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤២៥ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ

p

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៣/៦០៣ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៣
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៨៨អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ៣៦៩អបខ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ដីសរុបទំហំ ១.០៦៦,៩២ ហិកតា ក្នុងនោះ (១) ដីទំហំ ១.០៤៨,៣៣ ហិកតា កាត់ចេញពីដីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៦១៣/៦០៣ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៣ និង (២) ដីទំហំ ១៨,៥៩ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន HLH Agriculture និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មដីទំហំ ៩៦០,៣៩ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងដីទំហំ ១០៦,៥៣ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិច្រកទៀក ឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 84 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី១ ទី២ ទី៣ ទី៤ និងទី៥ នៃអនុក្រឹត្យនេះ ។

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៨២៥ គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិច្រកទៀក ឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ។

មាត្រា ៣..

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

មាត្រា ៤..

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៥២ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីទំហំ ៥៥៩,៤៧ ហិកតា នៅស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ក្នុងនោះ កាត់ចេញពី (១) ដីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ (២) ដីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤៨០ គ្រួសារ និងរក្សាទុកមួយចំណែក ជាដីសាធារណៈរបស់រដ្ឋ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី០១ខែវិច្ឆិកាឆ្នាំ១៩៩៣ស្តីពីការបង្កើតនិងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៣/៦០៤ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៨៨អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ៣៧១អបខ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ដីសរុបទំហំ ៥៥៩,៤៧ ហិកតា ក្នុងនោះ (១) ទំហំ ៤៧៦,៨៨ ហិកតា ចេញពីដីដែនជម្រកសត្វព្រៃភ្នំឱរ៉ាល់ ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៦១៣/៦០៤ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៣ និង (២) ទំហំ ៨២,៥៩ ហិកតា ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មដីទំហំ ៥៣៩,៤៨ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង និងដីទំហំ ២៩,៩៩ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិស្វាយទាប ឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 84 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋ ដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ៩៨០គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិស្វាយទាប ឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ។

p

មាត្រា ៣.-

ក្នុងពេលដំណើរការវាស់វែងនិងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែមិថុនា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៥៣ .អនក្រ.បក

អនុក្រឹត្យ

ស្ដីពី

ការកាត់ដីសរុបទំហំ ៤៣៣,៣០ ហិកតា នៅឃុំសុខសាន្ត ស្រុកកោះញែក ខេត្តមណ្ឌលគិរី ក្នុងនោះ កាត់ចេញពីដីដែនជម្រកសត្វព្រៃភ្នំព្រេច កាត់ចេញពីដីព្រៃការពារមណ្ឌលគិរី កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ព្រមទាំងកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ខេ សាន់ និងកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ថាច់ ខុង សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងរក្សាមួយចំណែកជាដីសាធារណៈរបស់រដ្ឋ និងការផ្ដល់សិទ្ធិលើក្បាលដី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្ដីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

p

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៣/៦០២ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ១៣១ លស.មគរ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តមណ្ឌលគិរី
- លិខិតលេខ ១៣៤ លស.មគរ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តមណ្ឌលគិរី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១..

ត្រូវបានកាត់ដីសរុបទំហំ ៨៣៣,៣០ ហិកតា ក្នុងនោះ (១) ទំហំ ២២១,៥០ ហិកតា កាត់ចេញពីដីដែនជម្រកសត្វព្រៃភ្នំព្រេច ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៦១៣/៦០២ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៣ (២) ទំហំ ៨៧,១៩ ហិកតា កាត់ចេញពីដីព្រៃការពារមណ្ឌលគិរី (៣) ទំហំ ១០១,៥៧ ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ (៤) ទំហំ ៩,២៩ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ខេ សាន់ និង (៥) ទំហំ ១៣,៨០ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ថាច់ វ្រដ សម្រាប់ធ្វើប្រទានកម្មទំហំ ៤១៨,៨៥ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងដីទំហំ ១៤,៤៥ ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិជីក្លប់ ឃុំសុខសាន្ត ស្រុកកោះញែក ខេត្តមណ្ឌលគិរី តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum wgs 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា ២..

ត្រូវបានប្រគល់អាណាត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តមណ្ឌលគិរី ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិជីក្លប់ ឃុំសុខសាន្ត ស្រុកកោះញែក ខេត្តមណ្ឌលគិរី ។

p

មាត្រា ៣.-

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុប ១៥១ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ១៥០ ក្បាលដី ជូនប្រជាពលរដ្ឋ ៧៧ គ្រួសារ និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ០១ ក្បាលដី (ដីសាលារៀន) ។

មាត្រា ៤.-

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តមណ្ឌលគិរី ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

មាត្រា ៥.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៦.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តមណ្ឌលគិរី ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែមិថុនា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៥៤.អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកាត់ដីសរុបទំហំ ៦៣១ ហិកតា នៅស្រុករវៀង ខេត្តព្រះវិហារ ក្នុងនោះ កាត់ចេញពីដីដែនជម្រកសត្វព្រៃប៉ឺងពែរ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ និងកាត់ចេញពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន ហ្វើនឈ័យ (ខេមបូឌា) ខូ លីមីតធីត សម្រាប់ធ្វើប្រទានកម្ម ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២០១ គ្រួសារ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២នសចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ

p

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦១៣/៥៩៩ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៣
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ០៥១/១៣ គ.គ្រ.ដ.រ.ខ ថ្ងៃទី ២០ ខែ ០៥ ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះវិហារ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១.-

ត្រូវបានកាត់ផ្ទៃដីសរុបទំហំ ៦៣១ ហិកតា ដែលក្នុងនោះ (១) ទំហំ ១៩៨.៥០ ហិកតា កាត់ចេញពីដីដែនជម្រកសត្វព្រៃបឹងពែរ ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៦១៣/៥៩៩ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៣ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ (២) ទំហំ ៤៣២.៥០ ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន ហ្វ្រីនឈ័យ (ខេមបូឌា) ខូ លីមីតធីត សម្រាប់ធ្វើប្រទានកម្មទំហំ ៥៩០.៣៦ ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ និងទំហំ ៤០.៦៤ ហិកតា រក្សាជាដីបម្រុងទុកសម្រាប់កំណើនប្រជាពលរដ្ឋ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត នៅភូមិស្វាយដំណាក់ថ្មី ឃុំមេទម ស្រុករវៀង ខេត្តព្រះវិហារ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

មាត្រា ២.-

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះវិហារ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង ចំនួន ២០១ គ្រួសារ នៅភូមិស្វាយដំណាក់ថ្មី ឃុំមេទម ស្រុករវៀង ខេត្តព្រះវិហារ ។

មាត្រា ៣.-

ក្នុងពេលដំណើរការវាស់វែង និងបែងចែកដាក់ស្លាក គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តព្រះវិហារ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៣៩៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពី

ការកាត់ដីទំហំ ១.៣៥៧,៥៨ ហិកតា នៅឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ចេញពីដីតម្រូវព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៤៧០ គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ និងការផ្តល់សិទ្ធិលើក្បាលដី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ

p

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៤ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ៨៦៨ ខបជ ចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបន្ទាយមានជ័យ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

មាត្រា ១..

ត្រូវបានកាត់ដីរដ្ឋទំហំ **១.៣៥៧,៩៨ ហិកតា** ចេញពីដីតម្របព្រៃឈើឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋទំហំ **១.៣៣០,០២ ហិកតា** សម្រាប់ធ្វើប្រទានកម្ម ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ៣៩១ គ្រួសារ និងទំហំ **២៧,៩៦ ហិកតា** រក្សាទុកជាដីសាធារណៈរបស់រដ្ឋ ដែលស្ថិតក្នុងភូមិក្បាលក្របី ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

មាត្រា ២..

ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបន្ទាយមានជ័យ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្តែង នៅភូមិក្បាលក្របី ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។

មាត្រា ៣..

ត្រូវបានផ្តល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដីសរុប ៦៨៤ ក្បាលដី ក្នុងនោះ ផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីឯកជន ៦៧៦ ក្បាលដី ជូនប្រជាពលរដ្ឋ ៣៩១ គ្រួសារ និងផ្តល់សិទ្ធិជាកម្មសិទ្ធិលើដីសាធារណៈរបស់រដ្ឋ ០៨ ក្បាលដី (ដីស្រះ ០១ក្បាល, ដីត្រពាំង ០១ក្បាលដី ដីទួល ០២ក្បាលដី ដីទួលកប់ខ្មោច ០១ក្បាលដី ដីសាលាឆទាន ០១ក្បាលដី ដីសាលារៀន ០១ក្បាលដី និងដីបំរុងទុកចាក់សំរាម ០១ក្បាលដី) ។

មាត្រា ៤..

ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តបន្ទាយមានជ័យ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន។

មាត្រា ៥..

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៦..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ០៦/៧ ឆ្នាំ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៩១ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ

សម្រេច

មាត្រា១..

បំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន៣២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានា នៅក្នុងវត្តប្រាសាទគោកបេង សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ ដូចមានរាយព្រះនាមនិងនាមខាងក្រោម ៖

ក-មេដាយប្រាក់ការងារ:

១-លោក	**ហ៊ីង**	**ឃឿន**	៣-លោកស្រី	**គួច**	**ឈាង**
២-សាស្ត្រាចារ្យ	**ប៊ុន**	**មុណ្យសាវ៉ាត់**			

ខ-មេដាយសំរឹទ្ធការងារ:

១-ព្រះគ្រូ	**ខាត់**	**សាខឿន**	១១-ឧបាសក	**សួរ**	**ពុធ**
២-ឧបាសក	**ឈុំ**	**ខុន**	១២-ឧបាសក	**សេង**	**គីមសេង**
៣-ឧបាសក	**ប៊ុន**	**វ៉ាន់**	១៣-ព្រះគ្រូ	**គោង**	**ហួន**
៤-ឧបាសក	**អិន**	**អឿន**	១៤-ឧបាសក	**ជិន**	**ចាន់**
៥-ឧបាសក	**សិន**	**សាញ់**	១៥-ឧបាសក	**ម៉ម**	**ជី**
៦-ឧបាសក	**ខាត់**	**សុវណ្ណារិន**	១៦-ឧបាសក	**សេង**	**ឆាយ**
៧-ឧបាសក	**ចាន់**	**ឃុំ**	១៧-ឧបាសក	**ហាម**	**បាន**
៨-ឧបាសក	**ប៉ាង**	**យាម**	១៨-ឧបាសក	**ម៉ាត់**	**ឡុន**
៩-ឧបាសក	**អ៊ុំ**	**អន**	១៩-ឧបាសក	**ចាន់**	**ធី**
១០-លោក	**អៀម**	**ម៉ី**	២០-លោក	**ឃឿង**	**ធីន**

p

២១-លោក	**ហ៊ុន ឡឿត**	២៦-ឧបាសក	**អ៊ុក គីមមិន**
២២-ឧបាសក	**ច សា**	២៧-អ្នកស្រី	**អ៊ុក ស្រីស្រស់**
២៣-ឧបាសក	**សេង ជា**	២៨-ឧបាសិកា	**ខឹម សុខុម**
២៤-ឧបាសក	**មិន សេង**	២៩-ព្រះគ្រូ	**ជ័យ សំរិទ្ធ**
២៥-ឧបាសិកា	**ម៉ី ណំ**		

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលនៃគណៈអភិបាលខេត្តព្រះវិហារ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ០៧ ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៨៩៧ .អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់មេបញ្ជាការកងទ័ពជើងគោក

សម្រេច

មាត្រា ១.-

បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូននាយទាហាន ចំនួន១៩រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ធិបឌិន្ទ

១- វរសេនីយ៍ត្រី **តែ ឡឿន** អត្តលេខ ០៣៧៤៣៥ មេបញ្ជាការវរសេនាតូចលេខ៥០៨ តំបន់ប្រតិបត្តិការសឹករងពោធិសាត់

២- វរសេនីយ៍ត្រី **ម៉ឹត ចេង** អត្តលេខ ០៣០៧៨៧ មេបញ្ជាការផ្នែកសឹករងវាលវែង តំបន់ប្រតិបត្តិការសឹករងពោធិសាត់

ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់សេនា

១- វរសេនីយ៍ត្រី **នួន សែ** អត្តលេខ ០៣០៧៨៨ មេបញ្ជាការរងវរសេនាតូចលេខ៥០៨ តំបន់ប្រតិបត្តិការសឹករងពោធិសាត់

២- វរសេនីយ៍ត្រី **ទេព ស៊ីណា** អត្តលេខ ០៧៦៦១២ មេបញ្ជាការរងវរសេនាតូចលេខ៥០៨ តំបន់ប្រតិបត្តិការសឹករងពោធិសាត់

៣- វរសេនីយ៍ត្រី **ម៉ឿន សាង** អត្តលេខ ១៣២៩៣៥ សេនាធិការ វរសេនាតូចលេខ៥០៨ តំបន់ប្រតិបត្តិការសឹករងពោធិសាត់

៤- អនុសេនីយ៍ឯក **សែ ឈឿត** អត្តលេខ ០៥៥៣៣៨ មេបញ្ជាការអនុសេនាធំទី១ វរសេនាតូចលេខ៥០៨ តំបន់ប្រតិបត្តិការសឹករងពោធិសាត់

៥- អនុសេនីយ៍ឯក **អ៊ុត ដារ៉ា** អត្តលេខ ០៦២៧៩៥ មេបញ្ជាការអនុសេនាធំគាំទ្រ វរសេនាតូចលេខ៥០៨ តំបន់ប្រតិបត្តិការសឹករងពោធិសាត់

៦- អនុសេនីយ៍ឯក **យ៉ែត សុជា** អត្តលេខ ០៣០៧៦៩ មេបញ្ជាការរងផ្នែកសឹករងវាលវែង តំបន់ប្រតិបត្តិការសឹករងពោធិសាត់

p

៧-	អនុសេនីយ៍ឯក	**សាន់**	**សុភឿន**	អត្តលេខ	០១៦២៩៦	មេបញ្ជាការរងផ្នែកសិក្សាវគ្គវាលវែង តំបន់ប្រតិបត្តិការសឹករងពោធិសាត់
៨-	អនុសេនីយ៍ឯក	**វឿន**	**ស៊ីនធី**	អត្តលេខ	២២៧៦៣៨	មេបញ្ជាការអនុសេនាធំ ផ្នែកសឹករងវាលវែង តំបន់ប្រតិបត្តិការសឹករងពោធិសាត
៩-	អនុសេនីយ៍ឯក	**ណៃរាជ**	**ថន្នី**	អត្តលេខ	០៥៥៣៨៣	មេបញ្ជាការអនុសេនាធំទី១ វរសេនាតូចលេខ៥០៨ តំបន់ប្រតិបត្តិការសឹករងពោធិសាត់
១០-	អនុសេនីយ៍ទោ	**ម៉ក់**	**ចាន់**	អត្តលេខ	១៣២៩០៨	មេបញ្ជាការរងផ្នែកសឹករងវាលវែង តំបន់ប្រតិបត្តិការសឹករងពោធិសាត់
១១-	អនុសេនីយ៍ត្រី	**សន**	**គិម**	អត្តលេខ	០៧៦៦៦៩	មេបញ្ជាការអនុសេនាធំទី២ វរសេនាតូចលេខ៥០៨ តំបន់ប្រតិបត្តិការសឹករងពោធិសាត់
១២-	អនុសេនីយ៍ត្រី	**ឡឿន**	**សុគី**	អត្តលេខ	០៦២៨២៩	មេបញ្ជាការអនុសេនាធំគាំទ្រ វរសេនាតូចលេខ៥០៨ តំបន់ប្រតិបត្តិការសឹករងពោធិសាត់
១៣-	អនុសេនីយ៍ត្រី	**ឡាំង**	**ឡឿន**	អត្តលេខ	០៥៥៣៨៦	មេបញ្ជាការរងអនុសេនាធំទី២ វរសេនាតូចលេខ៥០៨ តំបន់ប្រតិបត្តិការសឹករងពោធិសាត់
១៤-	នាយចំណង់	**សយ**	**ចាន់ធឿន**	អត្តលេខ	១៣៣០៣០	មេបញ្ជាការរងអនុសេនាធំគាំទ្រ វរសេនាតូចលេខ៥០៨ តំបន់ប្រតិបត្តិការសឹករងពោធិសាត់
១៥-	នាយចំណង់	**សេង**	**ម្រុស**	អត្តលេខ	១៣២៥៤៧	មេបញ្ជាការរងអនុសេនាតូចទី៣ អនុសេនាធំទី១ វរសេនាតូចលេខ៥០៨ តំបន់ប្រតិបត្តិការសឹករងពោធិសាត់
១៦-	ព្រិន្ទបាលឯក	**ឆាន**	**រដ្ឋា**	អត្តលេខ	០៩០៨៨៩	មេបញ្ជាការរងអនុសេនាធំទី២ វរសេនាតូចលេខ៥០៨ តំបន់ប្រតិបត្តិការសឹករងពោធិសាត់
១៧-	ព្រិន្ទបាលឯក	**ឈឹម**	**សារិទ្ធ**	អត្តលេខ	១៦៧០៥៩	មេបញ្ជាការរងអនុសេនាធំផ្នែកសឹករងវាលវែង តំបន់ប្រតិបត្តិការសឹករងពោធិសាត់

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងមេបញ្ជាការកងទ័ពជើងគោក ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៩៧.អនក្រ.បក

អនុក្រឹត្យ

ស្តីពីការដំឡើងមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់មេបញ្ជាការកងទ័ពជើងគោក

សម្រេច

មាត្រា ១.-

បំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូននាយទាហាន ចំនួន៩០រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមាសការងារ :

១-	វរសេនីយ៍ទោ	**ឈុំ**	**ស៊ុនណារ៉ា**	អត្តលេខ	០២២២៩៧	ជំនួយការ ឯកឧត្តម ងុម ហាក់
២-	វរសេនីយ៍ត្រី	**ព្រឹក**	**ធី**	អត្តលេខ	០៨៦៣១៤	នាយរងផ្នែកជ្រើសរើសទ័ព ការិយាល័យទី១ កងទ័ពជើងគោក
៣-	វរសេនីយ៍ត្រី	**លន**	**បរិសុទ្ធ**	អត្តលេខ	០២៦១៣១	នាយរងផ្នែកបូកសរុប ការិយាល័យទី២ កងទ័ពជើងគោក
៤-	វរសេនីយ៍ត្រី	**ទី**	**សុឡឿន**	អត្តលេខ	០១៦៥៩៦	នាយរងមណ្ឌល២ ការិយាល័យទី២ កងទ័ពជើងគោក
៥-	វរសេនីយ៍ត្រី	**ឈាន**	**ម៉ិន**	អត្តលេខ	០៤៨៦៩៥	នាយរងផ្នែកអប់រំវិន័យ ការិយាល័យទី២ កងទ័ពជើងគោក
៦-	វរសេនីយ៍ត្រី	**ហ៊ិន**	**សេខ**	អត្តលេខ	០២៦០៩៣	ជំនួយការកងឯកភាពសិល្បៈ ការិយាល័យទី៥ កងទ័ពជើងគោក
៧-	វរសេនីយ៍ត្រី	**ប៉ាំង**	**ខុម**	អត្តលេខ	០៣៩៥៨១	នាយផ្នែកលេខាធិការដ្ឋាន ការិយាល័យទី៥ កងទ័ពជើងគោក
៨-	អនុសេនីយ៍ឯក	**សុខ**	**ចំរើន**	អត្តលេខ	០១៤៧០២	ជំនួយការផ្នែកលេខាធិការដ្ឋាន ការិយាល័យទី២ កងទ័ពជើងគោក
៩-	អនុសេនីយ៍ឯក	**លឹម**	**ម៉ា**	អត្តលេខ	១១០០៩៨	ជំនួយការផ្នែកលេខាធិការដ្ឋាន ការិយាល័យទី២ កងទ័ពជើងគោក
១០-	អនុសេនីយ៍ឯក	**ជុំ**	**សាឡឿន**	អត្តលេខ	០២៦៣៤១	ជំនួយការផ្នែកស៊ើបការណ៍ ការិយាល័យទី២ កងទ័ពជើងគោក
១១-	អនុសេនីយ៍ឯក	**ឡឿន**	**ដារី**	អត្តលេខ	១០៦១៥១	នាយរងស្នាក់ការខេត្តកំពង់ធំ ការិយាល័យទី២ កងទ័ពជើងគោក

p

១២-	អនុសេនីយ៍ឯក	កែវ	កុសល	អត្តលេខ	០៦១០១៣	ជំនួយការផ្នែកលេខាធិការដ្ឋាន ការិយាល័យទី២ កងទ័ពជើងគោក
១៣-	អនុសេនីយ៍ឯក	មួច	ពិសី	អត្តលេខ	០៣៣៩៤៧	ជំនួយការផ្នែកលេខាធិការដ្ឋាន ការិយាល័យទី២ កងទ័ពជើងគោក
១៤-	អនុសេនីយ៍ឯក	ម៉ែន	សុធា	អត្តលេខ	០៤០៧០៧	នាយរងផ្នែកទំនាក់ទំនង ការិយាល័យអភិវឌ្ឍន៍ កងទ័ពជើងគោក
១៥-	អនុសេនីយ៍ឯក	ផែន	សាឡុន	អត្តលេខ	០៦៩០៩០	នាយរងផ្នែកដឹកជញ្ជូន ការិយាល័យទី៤ កងទ័ពជើងគោក
១៦-	អនុសេនីយ៍ឯក	ឃុត	ភារិទ្ធ	អត្តលេខ	០៣៤១៤៧	នាយរងផ្នែក គោលនយោបាយ ការិយាល័យទី៥ កងទ័ពជើងគោក
១៧-	អនុសេនីយ៍ឯក	ម៉ម	គន្ធា	អត្តលេខ	០៣៩៥៧១	ជំនួយការកងឯកភាពសិល្បៈ ការិយាល័យទី៥ កងទ័ពជើងគោក
១៨-	អនុសេនីយ៍ឯក	កែន	សុខន	អត្តលេខ	០២៦១២០	ជំនួយការកងឯកភាពសិល្បៈ ការិយាល័យទី៥ កងទ័ពជើងគោក
១៩-	អនុសេនីយ៍ឯក	ស្រី	ម៉ុនធឿន	អត្តលេខ	១០៩៤៥៩	ជំនួយការកងឯកភាពសិល្បៈ ការិយាល័យទី៥ កងទ័ពជើងគោក
២០-	អនុសេនីយ៍ឯក	ប៉ាល់	នី	អត្តលេខ	០៥៨៨៣៥	ជំនួយការកងឯកភាពសិល្បៈ ការិយាល័យទី៥ កងទ័ពជើងគោក
២១-	អនុសេនីយ៍ឯក	ទ្រៀក	ចំរើន	អត្តលេខ	២២៧៦១២	ជំនួយការ ព័តមានឯកសារ ការិយាល័យទី៥ កងទ័ពជើងគោក
២២-	អនុសេនីយ៍ឯក	អៀ	កៅតាខ	អត្តលេខ	០២៦១០២	ជំនួយការផ្នែកសង្គ្រាមចិត្តសាស្ត្រ ការិយាល័យទី៥ កងទ័ពជើងគោក
២៣-	អនុសេនីយ៍ឯក	សុត	ស៊ីម៉ុន	អត្តលេខ	០២៦២៨៨	នាយរងផ្នែកផែនការ ការិយាល័យអភិវឌ្ឍន៍ កងទ័ពជើងគោក
២៤-	អនុសេនីយ៍ឯក	តង់	ចាសនា	អត្តលេខ	០១៦០៨៣	ជំនួយការលេខាធិការដ្ឋាន ការិយាល័យអភិវឌ្ឍន៍ កងទ័ពជើងគោក
២៥-	អនុសេនីយ៍ឯក	មីន	មិន	អត្តលេខ	០៩០៧៦៨	ជំនួយការលេខាធិការដ្ឋាន មណ្ឌលអភិវឌ្ឍ ការិយាល័យអភិវឌ្ឍន៍ កងទ័ពជើងគោក
២៦-	អនុសេនីយ៍ឯក	អ៊ុង	ម៉ុណ្ណាចន្ទ្រា	អត្តលេខ	០៣៩០៤៦	នាយផ្នែកគ្រូបង្រៀន ការិយាល័យអភិវឌ្ឍន៍ កងទ័ពជើងគោក
២៧-	អនុសេនីយ៍ឯក	អ៊ុង	ធីរៈ	អត្តលេខ	២១០២៦១	ជំនួយការលេខាធិការដ្ឋាន ការិយាល័យអភិវឌ្ឍន៍ កងទ័ពជើងគោក
២៨-	អនុសេនីយ៍ឯក	ឌុយ	ប្រុស	អត្តលេខ	០៧៥៥៦៦	នាយក្រុមគម្រូតការងារ មណ្ឌលអភិវឌ្ឍន៍ ការិយាល័យអភិវឌ្ឍន៍ កងទ័ពជើងគោក
២៩-	អនុសេនីយ៍ឯក	សេង	ហួត	អត្តលេខ	១៣៤៦៤៨	នាយរងផ្នែកផលិតកម្មកែច្នៃ ការិយាល័យអភិវឌ្ឍន៍ កងទ័ពជើងគោក
៣០-	អនុសេនីយ៍ឯក	លី	សោភា	អត្តលេខ	០៤៤៦២៣	នាយរងផ្នែកផលិតកម្មកែច្នៃ ការិយាល័យអភិវឌ្ឍន៍ កងទ័ពជើងគោក
៣១-	អនុសេនីយ៍ឯក	តួច	ពិសិដ្ឋ	អត្តលេខ	០១៦៥០៦	ជំនួយការផ្នែកលេខាធិការដ្ឋាន ការិយាល័យអភិវឌ្ឍន៍ កងទ័ពជើងគោក
៣២-	អនុសេនីយ៍ឯក	កេត	ជុំ	អត្តលេខ	០៣០៧៧២	មេបញ្ជាការ អ.ធំទី១ វរសេនាតូចលេខ១៤៥ កងពលតូចអន្តរាគមន៍លេខ១៤
៣៣-	អនុសេនីយ៍ឯក	ជាញ់	ចន្ទ្រា	អត្តលេខ	០៥៥៣៦៥	មេបញ្ជាការរង អ ធំទី១ វរសេនាតូចលេខ១៤៥ កងពលតូចអន្តរាគមន៍លេខ១៤
៣៤-	អនុសេនីយ៍ឯក	សុខ	អុល	អត្តលេខ	០៣០៧៧៣	មេបញ្ជាការ អ.ធំទី២ វរសេនាតូចលេខ១៤៥ កងពលតូចអន្តរាគមន៍លេខ១៤
៣៥-	អនុសេនីយ៍ឯក	នៃ	ខួច	អត្តលេខ	០៤២៥០១	មេបញ្ជាការ អ.ធំទី៣ វរសេនាតូចលេខ១៤៥ កងពលតូចអន្តរាគមន៍លេខ១៤
៣៦-	អនុសេនីយ៍ឯក	ហាម	ហ៊ីន	អត្តលេខ	១៣២៤៧៤	មេបញ្ជាការរង អ.ធំទី៣ វរសេនាតូចលេខ១៤៥ កងពលតូចអន្តរាគមន៍លេខ១៤
៣៧-	អនុសេនីយ៍ឯក	ឃឹម	យ៉េត	អត្តលេខ	០៤៦១៤២	មេបញ្ជាការ អ.ធំទី៤ វរសេនាតូចលេខ១៤៥ កងពលតូចអន្តរាគមន៍លេខ១៤
៣៨-	អនុសេនីយ៍ឯក	ឈួន	ម៉ែត	អត្តលេខ	០៤២៥២៨	មេបញ្ជាការរង អ.ធំទី៤ វរសេនាតូចលេខ១៤៥ កងពលតូចអន្តរាគមន៍លេខ១៤
៣៩-	អនុសេនីយ៍ឯក	សៃ	តន	អត្តលេខ	០១៦៣០៦	មេបញ្ជាការ អ.ធំទី៥ វរសេនាតូចលេខ១៤៥ កងពលតូចអន្តរាគមន៍លេខ១៤
៤០-	អនុសេនីយ៍ឯក	មួច	ម៉េង	អត្តលេខ	០៤២៥២៤	មេបញ្ជាការរង អ.ធំទី៥ វរសេនាតូចលេខ១៤៥ កងពលតូចអន្តរាគមន៍លេខ១៤
៤១-	អនុសេនីយ៍ឯក	កែវ	សុផល	អត្តលេខ	០៨២០០៤	ជំនួយការប្រតិបត្តិការសឹក វរសេនាតូចលេខ១៤៥ កងពលតូចអន្តរាគមន៍លេខ១៤
៤២-	អនុសេនីយ៍ឯក	ស៊ឹម	សុភឿន	អត្តលេខ	០៥៥៣៥៤	ជំនួយការបុគ្គលិក វរសេនាតូចលេខ១៤៥ កងពលតូចអន្តរាគមន៍លេខ១៤
៤៣	អនុសេនីយ៍ឯក	សុទ្ធ	សុភា	អត្តលេខ	០៥៥៣៥២	ជំនួយការចលនូបត្ថម្ភ វរសេនាតូចលេខ១៤៥ កងពលតូចអន្តរាគមន៍លេខ១៤
៤៤-	អនុសេនីយ៍ឯក	ខួន	សេងហាក់	អត្តលេខ	០៧៦៥១២	ជំនួយការហិរញ្ញវត្ថុ វរសេនាតូចលេខ១៤៥ កងពលតូចអន្តរាគមន៍លេខ១៤
៤៥-	អនុសេនីយ៍ឯក	ពិន	សុភ័ក្ត្រ	អត្តលេខ	០៤៨៤៣៩	មេបញ្ជាការ អ ធំគាំទ្រ វរសេនាតូចលេខ១៤៥ កងពលតូចអន្តរាគមន៍លេខ១៤

៤៦- អនុសេនីយ៍ទោ ហ៊ីល ធី អត្តលេខ ១៣២៤៩២ មេបញ្ជាការរង ម.ធំទី២ វរសេនាតូចលេខ១៤៥ កងពលតូចអន្តរាគមន៍លេខ១៤

៤៧- អនុសេនីយ៍ទោ យ៉ឹន យ៉ុង អត្តលេខ ០៧៦៥៨៤ ជំនួយការពេទ្យ វរសេនាតូចលេខ១៤៥ កងពលតូចអន្តរាគមន៍លេខ១៤

៤៨- អនុសេនីយ៍ទោ ឡឹប ឡី អត្តលេខ ០៦២៨០៦ ជំនួយការហ្វឹកហ្វឺន វរសេនាតូចលេខ១៤៥ កងពលតូចអន្តរាគមន៍លេខ១៤

៤៩- អនុសេនីយ៍ទោ សេក សៅ អត្តលេខ ១៣២៣៦៦ មេបញ្ជាការ ម.តូចពិសេសជួន វរសេនាតូចលេខ១៤៥ កងពលតូចអន្តរាគមន៍លេខ១៤

៥០- អនុសេនីយ៍ទោ មោក សុខន អត្តលេខ ២២៧៦៣៦ ជំនួយការបុគ្គលិក វរសេនាតូចលេខ១៤៥ កងពលតូចអន្តរាគមន៍លេខ១៤

៥១- អនុសេនីយ៍ទោ ឆ្លុក ពន អត្តលេខ ០៧៦៥៧៣ មេបញ្ជាការ ម.តូចបញ្ជូនសារ វរសេនាតូចលេខ១៤៥ កងពលតូចអន្តរាគមន៍លេខ១៤

៥២- អនុសេនីយ៍ទោ ស្វាយ សារិទ្ធ អត្តលេខ ២១៨៦៦៦ មេបញ្ជាការរង ម.ធំទី១ វរសេនាតូចលេខ១៤៥ កងពលតូចអន្តរាគមន៍លេខ១៤

៥៣- អនុសេនីយ៍ទោ អ៊ុក សុផល អត្តលេខ ១៣៤៤៣៦ ជំនួយការផ្នែកលេខាធិការដ្ឋាន ការិយាល័យអភិវឌ្ឍន៍ កងទ័ពជើងគោក

៥៤- អនុសេនីយ៍ទោ សុខ លន់ អត្តលេខ ១៨៦៩១៩ ជំនួយការទំនាក់ទំនងសាធារណៈ ការិយាល័យទី៥ កងទ័ពជើងគោក

៥៥- អនុសេនីយ៍ត្រី ម៉ុល ចាសនា អត្តលេខ ១១២៩៨១ ជំនួយការផ្នែកលេខាធិការដ្ឋាន ការិយាល័យអភិវឌ្ឍន៍ កងទ័ពជើងគោក

៥៦- អនុសេនីយ៍ត្រី ខឹម ឈារ៉ុង អត្តលេខ ០៦៥៨២៧ មេបញ្ជាការរង អនុសេនាតូចទី១ កងពលតូចលេខ១១

៥៧- អនុសេនីយ៍ត្រី សួស សាមុត្រ អត្តលេខ ១៩០៣២៨ មេបញ្ជាការរង អនុសេនាតូចទី១ កងពលតូចលេខ៩១១ ដីក្រហម

៥៨- អនុសេនីយ៍ត្រី ចិន្តា គគ្គី អត្តលេខ ៦៩៩៩៧ មន្ត្រីនគរបាល ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង

៥៩- អនុសេនីយ៍ត្រី ស៊ី ម៉ុនរដ្ឋ អត្តលេខ ៦៩៨៩៩ មន្ត្រីនគរបាល ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង

៦០- នាយចំណង់ ជុះ ហាន អត្តលេខ ០៩០៨៤០ មេបញ្ជាការរង ម.ធំទី៣ វរសេនាតូចលេខ១៤៥ កងពលតូចអន្តរាគមន៍លេខ១៤

៦១- នាយចំណង់ រស់ ចេតនា អត្តលេខ ០៦២៨៣៦ មេបញ្ជាការ អនុសេនាតូចទី១ អនុសេនាធំទី៣ វរសេនាតូចលេខ៥០៨ តំបន់ប្រតិបត្តិការសឹករងពោធិ៍សាត់

៦២- នាយចំណង់ យ៉ី ទៅ អត្តលេខ ០៥៥៣៩១ មេបញ្ជាការ អនុសេនាតូចទី១ អនុសេនាធំទី៣ វរសេនាតូចលេខ៥០៨ តំបន់ប្រតិបត្តិការសឹករងពោធិ៍សាត់

៦៣- ព្រិន្ទបាលឯក ឆេង វិសាល អត្តលេខ ២១៨៨១៨ បុគ្គលិកបើកបរ ម.តូចពិសេសជួន វរសេនាតូចលេខ១៤៥ កងពលតូចអន្តរាគមន៍លេខ១៤

៦៤- ព្រិន្ទបាលឯក ខេង ថៃសាង អត្តលេខ ២០៦៤៩១ នាយក្រុមតម្រួតការពារ មណ្ឌលអភិវឌ្ឍន៍ ការិយាល័យអភិវឌ្ឍន៍ កងទ័ពជើងគោក

៦៥- ព្រិន្ទបាលឯក យ៉ី គង់ អត្តលេខ ០៧៦៥៥៦ មេបញ្ជាការ អនុសេនាតូចទី១ អនុសេនាធំទី៣ វរសេនាតូចលេខ៥០៨ តំបន់ប្រតិបត្តិការសឹករងពោធិ៍សាត់

៦៦- ព្រិន្ទបាលឯក ហួន ម៉ុនថេម អត្តលេខ ១៣២៤០៣ មេបញ្ជាការ អនុសេនាតូចទី៣ អនុសេនាធំទី២ វរសេនាតូចលេខ៥០៨ តំបន់ប្រតិបត្តិការសឹករងពោធិ៍សាត់

៦៧- ព្រិន្ទបាលឯក សែ ឈាង អត្តលេខ ០៧៦៥៣៩ មេក្រុម អនុសេនាតូចទី៣ អនុសេនាធំទី១ វរសេនាតូចលេខ៥០៨ តំបន់ប្រតិបត្តិការសឹករងពោធិ៍សាត់

ខ-មេដាយប្រាក់ការងារ :

១- វរសេនីយ៍ត្រី ឃុន ឆេង អត្តលេខ ០២២៣១០ នាយរងផ្នែកហ្វឹកហ្វឺន ការិយាល័យទី២ កងទ័ពជើងគោក

២- វរសេនីយ៍ត្រី ប្រាក់ សាន អត្តលេខ ០៥៤៩៣៣ នាយរងមណ្ឌល៤ ការិយាល័យទី២ កងទ័ពជើងគោក

៣- អនុសេនីយ៍ឯក ម៉ម សុផាណា អត្តលេខ ០៣៦៦២១ នាយរងស្នាក់ការ ខេត្តកណ្តាល ការិយាល័យទី២

៤- អនុសេនីយ៍ឯក ចាន់ ឡេង អត្តលេខ ១៨០០៤៤ ជំនួយការផ្នែកលេខាធិការដ្ឋាន ការិយាល័យទី២

៥- អនុសេនីយ៍ឯក ឆ្លុង វិរៈ អត្តលេខ ០៦៨៣៤៣ ជំនួយការផ្នែកលេខាធិការដ្ឋាន ការិយាល័យទី២

៦- អនុសេនីយ៍ឯក សិទ្ធ សិទ្ធី អត្តលេខ ០២២១២៤ នាយរងផ្នែកស៊ើបការណ៍ ការិយាល័យទី២

៧- អនុសេនីយ៍ឯក ទើន ជិត អត្តលេខ ០៤៨៦៥០ ជំនួយការខេត្ត មណ្ឌលគិរី ការិយាល័យទី២

p

៨-	អនុសេនីយ៍ឯក	យូ	តារា	អត្តលេខ	២១៩៥៥១	ជំនួយការផ្នែកលេខាធិការដ្ឋាន ការិយាល័យទី២
៩-	អនុសេនីយ៍ឯក	ម៉ម	គឹម	អត្តលេខ	០៩០០៤០	ជំនួយការមណ្ឌល៥ ការិយាល័យទី២
១០-	អនុសេនីយ៍ឯក	ខួន	ប្រាថ្នា	អត្តលេខ	២០៣៥៣៨	ជំនួយការលេខាធិការដ្ឋាន ការិយាល័យអភិវឌ្ឍន៍ កងទ័ពជើងគោក
១១-	អនុសេនីយ៍ឯក	ផៃ	រ័ត្ន	អត្តលេខ	១៤៧៩៤៤	ជំនួយការលេខាធិការដ្ឋាន ការិយាល័យអភិវឌ្ឍន៍ កងទ័ពជើងគោក
១២-	អនុសេនីយ៍ទោ	អឹម	ហៃ	អត្តលេខ	២២០៧០០	ជំនួយការលេខាធិការដ្ឋាន ការិយាល័យអភិវឌ្ឍន៍ កងទ័ពជើងគោក
១៣-	អនុសេនីយ៍ត្រី	ឡុច	សុខា	អត្តលេខ	០៣៦៧៥២	ជំនួយការលេខាធិការដ្ឋាន ការិយាល័យអភិវឌ្ឍន៍ កងទ័ពជើងគោក
១៤-	អនុសេនីយ៍ត្រី	អំ	សុគា	អត្តលេខ	០៤៦០៩០	ជំនួយការលេខាធិការដ្ឋាន ការិយាល័យទី៤ កងទ័ពជើងគោក
១៥-	ព្រឹន្ទបាលឯក	ឆត	ឈឿម	អត្តលេខ	០៧៦៦៤២	អ្នកបាញ់កាំភ្លើងត្បាល់៦០មម អនុសេនាធំទី១ វរសេនាតូចលេខ៥០៨ តំបន់ប្រតិបត្តិការសឹករងពោធិសាត់
១៦-	នាយឯក	ពុំ	ស៊ឹម	អត្តលេខ	១៣២៩០២	រងក្រុម អនុសេនាតូចទី៣ វរសេនាតូចលេខ៥០៨ តំបន់ប្រតិបត្តិការសឹករងពោធិសាត់

គ-មេដាយសិរីវឌ្ឍការងារ :

១-	អនុសេនីយ៍ឯក	ប្រិញ	សុផារី	អត្តលេខ	០៥៣៦៣៣	ជំនួយការស្នាក់ការខេត្តកំពង់ធំ ការិយាល័យទី២
២-	អនុសេនីយ៍ឯក	ម៉ី	សាគន្ធ	អត្តលេខ	០១៨៣២៨	ជំនួយការស្នាក់ការខេត្តកំពង់ធំ ការិយាល័យទី២
៣-	អនុសេនីយ៍ឯក	ម៉ុច	ឆា	អត្តលេខ	០៤០៤០១	ជំនួយការផ្នែកស្រាវជ្រាវ ការិយាល័យទី២
៤-	អនុសេនីយ៍ឯក	ម៉ុម	សំណាត	អត្តលេខ	២២៨៥៨០	ជំនួយការផ្នែកហ្វឹកហ្វឺន ការិយាល័យទី២
៥-	អនុសេនីយ៍ទោ	សុក្រ	សឿន	អត្តលេខ	០៥៦៧០២	ជំនួយការប្រតិការសឹក ផ្នែកសឹករងលើកដែក
៦-	អនុសេនីយ៍ត្រី	ខួច	មុត្រា	អត្តលេខ	២១៩៧១៣	ជំនួយការលេខាធិការដ្ឋាន ការិយាល័យអភិវឌ្ឍន៍ កងទ័ពជើងគោក
៧-	អនុសេនីយ៍ត្រី	ឡុច	គឹមណោច	អត្តលេខ	០៦០៦៨០	ជំនួយការផ្នែកបណ្តុះបណ្តាល ការិយាល័យអភិវឌ្ឍន៍ កងទ័ពជើងគោក

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងមេបញ្ជាការកងទ័ពជើងគោក ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ [illegible] ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៩៤ អនក្រ.បក

អនុក្រឹត្យ
ស្ដីពី
ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ បក ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្ដីពីការគ្រប់គ្រងការអនុវត្ត ការផ្លាស់ប្ដូរក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងផែនការ

សម្រេច

មាត្រា ១ : ប្រគល់ភារកិច្ចជូនលោក **ជា ចាន់តុលា** ឱ្យបំពេញមុខងារជាអគ្គនាយករង នៃវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៩៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ** ចំនួន ០១គ្រឿង ជូនលោក FREDDY WENS ទីប្រឹក្សាអន្តរជាតិផ្នែកនាវាចរណ៍ នៃរដ្ឋ Flanders ប្រទេសប៊ែលហ្ស៊ិក ដែលបានឧបត្ថម្ភ ក្នុងការរៀបចំចងក្រងនូវហេដ្ឋារចនាសម្ព័ន្ធផ្នែកច្បាប់ សម្រាប់វិស័យដឹកជញ្ជូនតាមផ្លូវទឹក ព្រមទាំងជួយបណ្តុះបណ្តាលមន្ត្រីនាយកដ្ឋានជំនាញបានជាច្រើននាក់ ទទួលបានលទ្ធផលល្អប្រសើរ។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៨៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការដំឡើងឋានន្តរស័ក្តិនាយនគរបាលជាន់ខ្ពស់

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ដំឡើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ៖

១- លោកវរសេនីយ៍ទោ **ផុ ស្រេង** អត្តលេខ ០៩៧៨

២- លោកវរសេនីយ៍ទោ **ម៉ុនប៉ា ម៉ារីណុច** អត្តលេខ ៥៥៥៥៦

៣- លោកវរសេនីយ៍ទោ **ចាន់ ធូរ៉ែន** អត្តលេខ ០១៤៥៣

៤- លោកវរសេនីយ៍ទោ **សុខ សុគន្ធ** អត្តលេខ ០៩០៤៣

៥- លោកវរសេនីយ៍ទោ **យៀង សុគន្ធា** អត្តលេខ ០៧០៦៦ ។

p

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ ៧ ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៩៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល នៃមន្ទីរពេទ្យព្រះអង្គឌួង

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល

-បានឃើញអនុក្រឹត្យលេខ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញអនុក្រឹត្យលេខ១៩៥ អនក្រ.បក ចុះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១២ ស្តីពីការប្រែក្លាយមន្ទីរពេទ្យព្រះអង្គឌួងជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សម្រេច

មាត្រា១.-

តែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលនៃមន្ទីរពេទ្យព្រះអង្គឌួង ដូចមានរាយនាមខាងក្រោម ៖

១-ឯកឧត្តម	**យឹត ស៊ុនណារ៉ា**	តំណាងក្រសួងសុខាភិបាល	ប្រធាន
២-លោក	**សារុន រ៉ាឌី**	តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក

p

៣-លោក **ប៉ា សុខុម** តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៤-លោកជំទាវ **អ៊ុំ សារ៉ុល** តំណាងឥស្សរជនមានចំណេះដឹងនិងបទពិសោធន៍ខាងវិទ្យាសាស្ត្រសុខាភិបាល សមាជិក

៥-លោកស្រី **គឹម សេដ្ឋានី** តំណាងសាលារាជធានីភ្នំពេញ សមាជិក

៦-លោកវេជ្ជបណ្ឌិត **លូ លីឃាង** នាយកមន្ទីរពេទ្យព្រះអង្គឌួង សមាជិកស្វ័យប្រវត្តិ

៧-លោកវេជ្ជបណ្ឌិត **ជុង ម៉េងឡុង** តំណាងបុគ្គលិកមន្ទីរពេទ្យព្រះអង្គឌួង សមាជិកស្វ័យប្រវត្តិ។

មាត្រា២.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

មាត្រា៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សាលារាជធានីភ្នំពេញ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៧៥ អនក្រ.បក

ជាតិ សាសនា ព្រះមហាក្សត្រ

អនុក្រឹត្យ
ស្តីពី
ការជូន គ្រឿងឥស្សរិយយស

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី។
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា។
- តាមសំណើរបស់សម្តេចចៅហ្វាវាំង **គង់ សំអុល** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង និងជាប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ។

សម្រេច

មាត្រា ១ : បំពាក់ **គ្រឿងឥស្សរិយយស** តាមប្រភេទ និង លំដាប់ថ្នាក់ ជូនមន្ត្រីរាជការ និងកងកំលាំងប្រដាប់អាវុធ ចំនួន ២៥៣ រូប ដែលមានស្នាដៃល្អក្នុងការចូលរួមបំពេញភារកិច្ច រៀបចំព្រះរាជពិធីបុណ្យទ្វាទសមាស និងពិធីបដិសណ្ឋារកិច្ចភ្ញៀវជាន់ខ្ពស់ជាតិ អន្តរជាតិ ដូចមានរាយនាមខាងក្រោម :

ក. មេដាយមាសការងារ :

១- ឯកឧត្តម	**សុរិន្ទ្រ វិរមុនី**	២- លោក	**ផុន សុផាត**
៣- លោក	**ជា កុមារះត្ន**	៤- លោក	**សុខ ពិសិដ្ឋ**
៥- លោក	**ឡុង សេរីរត្ន**	៦- លោក	**ម៉ែន .សំអុល**
៧- លោក	**ទិន តុ**	៨- លោក	**នី នាង**
៩- លោក	**គួច លី**	១០ លោក	**វណ្ណ ច័ន្ទសុផល**
១១- លោក	**សល់ វណ្ណានី**	១២ លោក	**ស៊ិន សំអន**

p

១៣- លោក	ម៉ែន សុន្ធា	១៤- លោក	ស៊ិន ជួងកែវ
១៥- លោក	ម៉ម ស៊ុមន	១៦- លោកស្រី	អ៊ុន សុចន្ធា
១៧- លោក	ចក់ គង់	១៨- លោក	ជួន ចរិយា
១៩- លោក	ឆន តៅ	២០- លោកស្រី	យឹម ម៉ាណែត
២១- លោកស្រី	ទេព ឈុនលី	២២- លោក	ជៀម ចន់
២៣- លោក	ខុយ ចំនួនកក្កដា	២៤- លោក	ស្ងួត ចំនួនតារា
២៥- លោក	អ៊ី ទូចឆ្លរ	២៦- លោក	ឡៅ សុខបុប្ផា
២៧- លោក	ស្ងើច វិចិត្រ	២៨- លោក	ណែត សីហា
២៩- លោក	គង់ បញ្ញា	៣០- ឧត្តមសេនីយ៍ត្រី	គង់ មនោ
៣១- វរសេនីយ៍ទោ	យី ដារ៉ា	៣២- វរសេនីយ៍ទោ	សេង ទីរ៉ាឌុច
៣៣- វរសេនីយ៍ត្រី	ពូត គយ	៣៤- វរសេនីយ៍ត្រី	សុខ សុវណ្ណ
៣៥- វរសេនីយ៍ត្រី	សែន សំអឿន	៣៦- វរសេនីយ៍ត្រី	ម៉ុម ពិសី
៣៧- វរសេនីយ៍ត្រី	ឌិន ធានុ	៣៨- វរសេនីយ៍ត្រី	ជុន ទីណុង
៣៩- វរសេនីយ៍ត្រី	ឆន់ សំអយ	៤០- វរសេនីយ៍ត្រី	សៀក សុខ
៤១- វរសេនីយ៍ត្រី	ហេង ប៉ូលីន	៤២- វរសេនីយ៍ត្រី	ឆេង ពិសិដ្ឋ
៤៣- អនុសេនីយ៍ឯក	ប៊ី បុណ្ណា	៤៤- អនុសេនីយ៍ឯក	យី យ៉ា
៤៥- អនុសេនីយ៍ឯក	ម៉ៅ ម៉ុនថន	៤៦- អនុសេនីយ៍ឯក	សាំង ផេង
៤៧- អនុសេនីយ៍ឯក	ជា ឡេង	៤៨- អនុសេនីយ៍ឯក	តែ បុណ្ណាទី
៤៩- អនុសេនីយ៍ឯក	ជា បូរិន្ទ	៥០- អនុសេនីយ៍ឯក	ជិត ចាន់ថន
៥១- អនុសេនីយ៍ឯក	ស៊ាង ផាលី	៥២- អនុសេនីយ៍ឯក	សុំ រ៉ាយូ
៥៣- អនុសេនីយ៍ឯក	ជា សាមិត្ត	៥៤- អនុសេនីយ៍ឯក	ផុល អូនី
៥៥- អនុសេនីយ៍ឯក	វិចិត្រ សក្តិ	៥៦- អនុសេនីយ៍ឯក	លន់ ចាន់រ៉ាឌីបូ
៥៧- អនុសេនីយ៍ឯក	នាង គុងហេង	៥៨- អនុសេនីយ៍ឯក	យ៉េត កែវឧត្តម
៥៩- អនុសេនីយ៍ឯក	ប៊ិច សុភាព	៦០- អនុសេនីយ៍ឯក	ឃុត សោភ័ណ្ឌ
៦១- អនុសេនីយ៍ឯក	កុច ជាតិ	៦២- អនុសេនីយ៍ឯក	នី គន្ធី
៦៣- អនុសេនីយ៍ឯក	ជា រិទ្ធី	៦៤- អនុសេនីយ៍ឯក	ផាត់ ចន្ធី
៦៥- អនុសេនីយ៍ឯក	សួស សុធារិទ្ធិ	៦៦- លោកស្រីអនុសេនីយ៍ទោ	ឆេង ធីតា
៦៧- អនុសេនីយ៍ទោ	ក្រាក់ សុខ	៦៨- អនុសេនីយ៍ទោ	ហាស វណ្ណៈ
៦៩- អនុសេនីយ៍ទោ	ញាន ធីរូត	៧០- អនុសេនីយ៍ទោ	ញ៉ឹម គីណា
៧១- អនុសេនីយ៍ទោ	ខុម រី	៧២- អនុសេនីយ៍ទោ	សឿន សុតាក់
៧៣- អនុសេនីយ៍ទោ	សុខ ផានិត	៧៤- អនុសេនីយ៍ទោ	ណៃ សំឡៀង
៧៥- អនុសេនីយ៍ទោ	គ្រឹក សារ៉ែន	៧៦- អនុសេនីយ៍ទោ	ម៉េង ចន្ទី
៧៧- អនុសេនីយ៍ទោ	ណៃ សំអឿន	៧៨- អនុសេនីយ៍ទោ	ចេក តារុន
៧៩- អនុសេនីយ៍ទោ	គុយ ថា	៨០- អនុសេនីយ៍ទោ	ម៉ៅ គឹមឡា
៨១- អនុសេនីយ៍ទោ	ខាន់ ម៉ុនឡា	៨២- អនុសេនីយ៍ទោ	យ៉ាង វិចិត្រ

៨៣	អនុសេនីយ៍ទោ	អ៊ុក រតនា	៨៤-	អនុសេនីយ៍ទោ	សេខ ឈូករ័ដ្ឋ
៨៥-	អនុសេនីយ៍ទោ	មិន ចាន់	៨៦-	អនុសេនីយ៍ទោ	សេខ សុខា
៨៧-	អនុសេនីយ៍ទោ	ខឹម គីណាល់	៨៨-	អនុសេនីយ៍ទោ	ស៊ៀន សុខរដ្ឋ
៨៩-	អនុសេនីយ៍ទោ	ភួន ខុំ	៩០-	អនុសេនីយ៍ទោ	ឈឹម សុផាត
៩១-	អនុសេនីយ៍ទោ	អ៊ុក សារ៉ាត់	៩២-	អនុសេនីយ៍ទោ	ស៊ូ ផន
៩៣-	អនុសេនីយ៍ទោ	សំ ពិសិដ្ឋ	៩៤-	អនុសេនីយ៍ទោ	នង ដារ៉ា
៩៥-	អនុសេនីយ៍ទោ	អ៊ិន អេង	៩៦-	អនុសេនីយ៍ទោ	ជិន ជៀន
៩៧-	អនុសេនីយ៍ទោ	កៅ សុខមាន	៩៨-	អនុសេនីយ៍ទោ	ស៊ុយ សារ៉េត
៩៩-	អនុសេនីយ៍ទោ	ឡាត់ សិលា	១០០-	អនុសេនីយ៍ទោ	ឈួន ចំរើន
១០១-	អនុសេនីយ៍ទោ	គីម វណ្ណះ	១០២-	អនុសេនីយ៍ទោ	មិន ហត្ថា
១០៣-	អនុសេនីយ៍ទោ	ស៊ុន កាន់ណារ័ត្ន	១០៤-	អនុសេនីយ៍ទោ	នូ ពន្លាច
១០៥-	អនុសេនីយ៍ទោ	ឌៀង គង់	១០៦-	អនុសេនីយ៍ទោ	ឡាំង ឌី
១០៧-	អនុសេនីយ៍ទោ	កែវ សំណាង	១០៨-	អនុសេនីយ៍ទោ	ណន ណាត
១០៩-	អនុសេនីយ៍ទោ	តួយ ឈាវ	១១០-	អនុសេនីយ៍ទោ	ម៉ុន សុត៌ក្រ
១១១-	អនុសេនីយ៍ទោ	អែម សុធាវី	១១២-	អនុសេនីយ៍ទោ	អ៊ុច សុគន្ធពិដោ
១១៣-	អនុសេនីយ៍ទោ	កែវ ស៊ីណាត	១១៤-	អនុសេនីយ៍ត្រី	ហៃ ហឿត
១១៥-	អនុសេនីយ៍ត្រី	ម៉ាង ដា	១១៦-	អនុសេនីយ៍ត្រី	ត្រាប ស្រួយ
១១៧-	អនុសេនីយ៍ត្រី	មិន សុផល	១១៨-	អនុសេនីយ៍ត្រី	ចន ភាដែត
១១៩-	អនុសេនីយ៍ត្រី	សែត រ័ត្ន	១២០-	អនុសេនីយ៍ត្រី	អៀង វណ្ណា
១២១-	អនុសេនីយ៍ត្រី	សើ ស៊ីណាត	១២២-	អនុសេនីយ៍ត្រី	ខិន សារុន
១២៣-	អនុសេនីយ៍ត្រី	ចែម សំអាត	១២៤-	អនុសេនីយ៍ត្រី	ហេង សំបូរ
១២៥-	អនុសេនីយ៍ត្រី	យួន កែវសុគន្ធ	១២៦-	អនុសេនីយ៍ត្រី	ម៉ឿន រតនៈ
១២៧-	អនុសេនីយ៍ត្រី	ធឿន ចិត្រា	១២៨-	អនុសេនីយ៍ត្រី	សាន សុខ
១២៩-	អនុសេនីយ៍ត្រី	សំ រ៉ាយុទ្ធ	១៣០-	អនុសេនីយ៍ត្រី	អ៊ុក សុភាព
១៣១-	អនុសេនីយ៍ត្រី	ឡាយ ម៉ៅ	១៣២-	អនុសេនីយ៍ត្រី	សុគន្ធ កែវកល្យាណ
១៣៣-	អនុសេនីយ៍ត្រី	ភាន់ ភក្តី	១៣៤-	អនុសេនីយ៍ត្រី	លន់ សោ
១៣៥-	អនុសេនីយ៍ត្រី	ឈួន រតនា	១៣៦-	អនុសេនីយ៍ត្រី	មាស សាវុធ
១៣៧-	អនុសេនីយ៍ត្រី	ហែម ចាន់ភារិទ្ធ	១៣៨-	អនុសេនីយ៍ត្រី	ធឿន សារិទ្ធ
១៣៩-	អនុសេនីយ៍ត្រី	ចុក ចន្ធូ	១៤០-	អនុសេនីយ៍ត្រី	នួន សុខ្លា
១៤១-	អនុសេនីយ៍ត្រី	ម៉ុន សុវណ្ណា	១៤២-	អនុសេនីយ៍ត្រី	ចេក សារ៉េន
១៤៣-	អនុសេនីយ៍ត្រី	ឈឿន វែង	១៤៤-	អនុសេនីយ៍ត្រី	មូ ទ្រី
១៤៥-	អនុសេនីយ៍ត្រី	ស សំអឿន	១៤៦-	អនុសេនីយ៍ត្រី	ស៊ឹម ចាន់ថន
១៤៧-	អនុសេនីយ៍ត្រី	ឡឿ ភូរិទ្ធ	១៤៨-	អនុសេនីយ៍ត្រី	ម៉ាន់ ម៉ៅ

១៤៩-	អនុសេនីយ៍ត្រី	សេក កុសល	១៥០-	អនុសេនីយ៍ត្រី	ម៉ែន បុន្សាទី
១៥១-	អនុសេនីយ៍ត្រី	ញៀក ចាន់ថុល	១៥២-	អនុសេនីយ៍ត្រី	សាយ ដា
១៥៣-	អនុសេនីយ៍ត្រី	ថន វណ្ណថា	១៥៤-	អនុសេនីយ៍ត្រី	វេត សុគុម
១៥៥-	អនុសេនីយ៍ត្រី	នៅ សារ៉ាត់	១៥៦-	អនុសេនីយ៍ត្រី	ប៊ុន សាធុច
១៥៧-	អនុសេនីយ៍ត្រី	ខន់ លីន	១៥៨-	អនុសេនីយ៍ត្រី	មោ ពៅ
១៥៩-	អនុសេនីយ៍ត្រី	ស្រេង គ្រួយ	១៦០-	អនុសេនីយ៍ត្រី	ព្រហ្ម ម៉ាលី
១៦១-	អនុសេនីយ៍ត្រី	សំ ចរិយា	១៦២-	អនុសេនីយ៍ត្រី	គុល ម៉ុល្លី
១៦៣-	អនុសេនីយ៍ត្រី	ស៊ិន ស៊ីវន	១៦៤-	អនុសេនីយ៍ត្រី	ឡេង ប៊ុនឡុង
១៦៥-	អនុសេនីយ៍ត្រី	ឃុត សេរីភោគ	១៦៦-	អនុសេនីយ៍ត្រី	ឡុច រតន៍
១៦៧-	អនុសេនីយ៍ត្រី	មាស ចាន់	១៦៨-	អនុសេនីយ៍ត្រី	យស់ តេអូ
១៦៩-	អនុសេនីយ៍ត្រី	លៀម ខេង	១៧០-	អនុសេនីយ៍ត្រី	មុត កុសលជាតិ
១៧១-	អនុសេនីយ៍ត្រី	ម៉ែន សុខា	១៧២-	អនុសេនីយ៍ត្រី	ឡាយ ផៃលន់
១៧៣-	អនុសេនីយ៍ត្រី	ឡាញ់ សុធា	១៧៤-	អនុសេនីយ៍ត្រី	ឈិត ធុន្ធី
១៧៥-	អនុសេនីយ៍ត្រី	ឈុន ស្រ៊ុន	១៧៦-	អនុសេនីយ៍ត្រី	ជាង សុធឿន
១៧៧-	អនុសេនីយ៍ត្រី	សារ៉ាន ធុត្តា	១៧៨-	អនុសេនីយ៍ត្រី	អ៊ុង ធុជផែល
១៧៩-	អនុសេនីយ៍ត្រី	សូ រតនា	១៨០-	អនុសេនីយ៍ត្រី	សរ សំណាង
១៨១	អនុសេនីយ៍ត្រី	ជៀប ឡុន	១៨២-	អនុសេនីយ៍ត្រី	សុប សេន
១៨៣-	អនុសេនីយ៍ត្រី	អៀង ជ័យមករា	១៨៤-	លោកស្រីអនុសេនីយ៍ត្រី	ឆន ស៊ុនួន
១៨៥-	នាយចំណង់	រួន រ៉ា	១៨៦-	នាយចំណង់	ជឿម សេរី
១៨៧-	នាយចំណង់	សែម ខឿន	១៨៨-	នាយចំណង់	ហ៊ីត ចន្ទខេត
១៨៩-	នាយចំណង់	ជា រ៉ូម៉ានី	១៩០-	នាយចំណង់	អួន សំអុល
១៩១-	នាយចំណង់	តែម យ៉ារី	១៩២-	នាយចំណង់	ទឹម ប៊ុនធឿន
១៩៣-	ព្រិន្ទបាលឯក	ផល វណ្ណៈ	១៩៤-	ព្រិន្ទបាលឯក	ទៃ ម៉េងហុង
១៩៥-	ព្រិន្ទបាលឯក	សឿន សៀន	១៩៦-	ព្រិន្ទបាលឯក	សេង គីមស៊ិន
១៩៧-	ព្រិន្ទបាលឯក	សាំង សុផារ័ត្ន	១៩៨-	ព្រិន្ទបាលឯក	ស៊ុំ ណារិទ្ធ
១៩៩-	ព្រិន្ទបាលឯក	ស្រី ប៊ុនធា	២០០-	ព្រិន្ទបាលឯក	អ៊ុំ សោភ័ណ្ឌ
២០១-	ព្រិន្ទបាលឯក	គ្រឿង សុខហេង	២០២-	ព្រិន្ទបាលឯក	ឌុល ម៉ាន់
២០៣-	ព្រិន្ទបាលឯក	ខៀវ ឌុន	២០៤-	ព្រិន្ទបាលឯក	ឆាយ សារី
២០៥-	ព្រិន្ទបាលឯក	ថៃ ហួរ	២០៦-	ព្រិន្ទបាលឯក	មោ តារារិទ្ធ
២០៧-	ព្រិន្ទបាលឯក	ម៉ុម ឆាងសម័យ	២០៨-	ព្រិន្ទបាលឯក	អ៊ុំ សំណាង
២០៩-	ព្រិន្ទបាលឯក	ហេង សុផាណារ៉ាត់	២១០-	ព្រិន្ទបាលឯក	ម៉ែន ចំណាប់
២១១	ព្រិន្ទបាលឯក	សំ ឧត្តម	២១២-	ព្រិន្ទបាលទោ	ស៊ីង រស្មី
២១៣-	ព្រិន្ទបាលទោ	តែម ប៊ូលីន	២១៤-	ព្រិន្ទបាលទោ	គួន ឡេងស្រ៊ុន

២១៥-	ព្រិន្ទបាលទោ	មី សំរេច	២១៦-	ព្រិន្ទបាលទោ	ហៀង សីហៈ
២១៧-	ព្រិន្ទបាលទោ	ហៀត ហឿន	២១៨-	ព្រិន្ទបាលទោ	យឹម កុសល
២១៩-	ព្រិន្ទបាលទោ	ក្រាច ភារៈ	២២០-	ព្រិន្ទបាលទោ	ផុន ប៊ុនធឿន
២២១-	ព្រិន្ទបាលទោ	ផាន់ វិរម៉េត	២២២-	ព្រិន្ទបាលទោ	សេ សាម៉ន
២២៣-	ព្រិន្ទបាលទោ	ហ៊ុយ សុគន្ធ	២២៤-	ព្រិន្ទបាលទោ	ម៉ាន់ ដារ៉ា
២២៥-	ព្រិន្ទបាលទោ	កែវ ពិសិដ្ឋ	២២៦-	កញ្ញាព្រិន្ទបាលទោ	កែវ ពិសី
២២៧-	ពលបាលឯក	អ៊ុក ប៊ុនថន	២២៨-	ពលបាលឯក	គេង ចំរើនថារ័ត្ន
២២៩-	ពលបាលឯក	ហ៊ន សំអុន	២៣០-	លោក	ជា ធុនា

ខ. មេដាយប្រាក់ការងារ :

១-	លោក	ស៊ូ គិរម្យ	២-	លោក	ទេព គិរុណា
៣-	លោក	ពេជ្រ រ៉ាមី	៤-	លោក	ឱុច សុទី
៥-	លោកស្រី	ឈឹម សោភណ្ណារី	៦-	លោក	ខៀវ ផាន់ណា
៧-	លោក	ជា ពិសាល	៨-	អនុសេនីយ៍ត្រី	ឆន់ កៅនី
៩-	អនុសេនីយ៍ត្រី	ខែម សុម៉ាលី	១០-	អនុសេនីយ៍ត្រី	សូស រដ្ឋា
១១-	អនុសេនីយ៍ត្រី	នាង វីជា	១២-	អនុសេនីយ៍ត្រី	ឡាយ សំអឿន
១៣-	អនុសេនីយ៍ត្រី	សិរិឆ្ន ផល្លី	១៤-	អនុសេនីយ៍ត្រី	ស៊ិន គំសត់
១៥-	អនុសេនីយ៍ត្រី	ប៊ុន ឡឿន	១៦-	ព្រិន្ទបាលឯក	ញ៉ាន់ សំណាង
១៧-	ព្រិន្ទបាលឯក	សាំង សុខ	១៨-	ព្រិន្ទបាលទោ	គង់ ប៊ុរិន
១៩-	ពលបាលឯក	ឈុម ធីរៈ			

គ. មេដាយសំរិទ្ធការងារ :

១-	លោក	ម៉ែត សុគី	២-	លោក	ផុន ស៊ូរីតា
៣-	លោក	មច្ឆ សាម៉ាត	៤-	លោកស្រី	អ៊ីវ ច័ន្ទធុល

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អប្រសើរ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មេសា ឆ្នាំ ២០១៣

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៤៩៥ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៥៦ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីក្រមការ

-បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្ត ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ របស់មន្ត្រីរាជការស៊ីវិល

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

សម្រេច

មាត្រា ១ : ប្រគល់ភារកិច្ចជូនលោកស្រី **ប្រុក ម៉ៃអត្ថិដ្ឋា** ក្រមការដើមខ្សែ ថ្នាក់លេខ៩ ឲ្យបំពេញមុខងារជាអគ្គាធិការរងនៃអគ្គាធិការដ្ឋាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ២០១៣

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

-ក្រសួងព្រះបរមរាជវាំង

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-ដូចមាត្រា ២

-រាជកិច្ច

-ឯកសារ កាលប្បវត្តិ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥០០ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការតែងតាំងទីប្រឹក្សា និងជំនួយការក្រសួងមហាផ្ទៃ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុងស្រុក ខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

ក-១-៣- ថ្នាក់រដ្ឋបាលខណ្ឌ និងសង្កាត់ចំណុះរាជធានី ការរៀបចំគម្រោងចំណូលត្រូវផ្អែកលើកញ្ចប់ថវិកាដែលបានបែងចែកនិងជូនដំណឹងពីរដ្ឋបាលរាជធានី។

ក-១-៤- ថ្នាក់រដ្ឋបាលសង្កាត់ចំណុះក្រុង ការរៀបចំគម្រោងចំណូលត្រូវផ្អែកលើកញ្ចប់ថវិកាដែលបានបែងចែកនិងជូនដំណឹងពីរដ្ឋបាលក្រុង។

ក-១-៥- ថ្នាក់រដ្ឋបាលឃុំ ការរៀបចំគម្រោងចំណូលត្រូវផ្អែកលើតួលេខដែលបានវិភាជន៍ និងផ្ទេរពីថ្នាក់ជាតិនូវមូលនិធិឃុំ សង្កាត់ដែលក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានជូនដំណឹងតាមរយៈរដ្ឋបាលខេត្តនិងចំណូលរដ្ឋបាលផ្សេងៗដែលប្រមូលបាននៅមូលដ្ឋានរបស់ឃុំ។

ក-២- គម្រោងចំណូលមូលធន

ចំណូលជាមូលធននៃថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗអាចបានមកពីការផ្ទេរឥណទានពីថវិកាថ្នាក់ជាតិ និងចំណូលមូលធនដែលមានប្រភពនៅនឹងមូលដ្ឋានផ្ទាល់។ ដូចនេះពេលរៀបចំគម្រោងចំណូលជាមូលធនគ្រប់ថ្នាក់នីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវយកចិត្តទុកដាក់កត់ត្រាបញ្ចូលឲ្យអស់នូវជំនួយមនុស្សធម៌និងជំនួយពីបរទេសដែលសប្បុរសជន អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលនានាបានសន្យាផ្តល់ហិរញ្ញប្បទានផ្ទាល់ដល់ថវិការបស់រដ្ឋបាលនីមួយៗរួចហើយ។

ខ- អំពីគម្រោងចំណាយ

ចំណាយសរុបថវិការដ្ឋឆ្នាំ២០១៤ ត្រូវរក្សាឲ្យនៅត្រឹម២០,១៣% នៃផ.ស.ស (ថ្នាក់ជាតិ១៩,៣៣% និងថ្នាក់ក្រោមជាតិ០,៩៩%) ដោយចំណាយចរន្តថវិការដ្ឋនឹងកម្រិតត្រឹម១២,០៦%នៃផ.ស.ស(ថ្នាក់ជាតិ ១១,៤៧% និងថ្នាក់ក្រោមជាតិ០,៧៨%) ក្នុងនោះរាជរដ្ឋាភិបាលកំពុងរៀបចំកែលម្អប្រព័ន្ធបៀវត្ស និងរៀបចំគោលនយោបាយដំឡើងប្រាក់បៀវត្សដោយផ្អែកលើកំណើនសេដ្ឋកិច្ច អតិផរណា និងលទ្ធភាពថវិកា ក្នុងទិសដៅលើកកម្ពស់ផលិតភាពការងារ បង្កើនប្រសិទ្ធិភាពនៃការផ្តល់សេវាសាធារណៈ និងធានាបាននូវសមធម៌ ព្រមទាំងរក្សាបាននូវស្ថេរភាព និងចីរភាពហិរញ្ញវត្ថុសាធារណៈ និងម៉ាក្រូសេដ្ឋកិច្ច។ ថវិការាជធានី ខេត្ត ត្រូវកំណត់ត្រឹម

p

០,៩៩% នៃ ផ.ស.ស ដែលក្នុងនោះថវិកាផ្ទាល់របស់រាជធានី ខេត្តសរុបមានប្រមាណ០,៧៩% នៃផ.ស.ស មានកំណើន០,០៩% នៃផ.ស.ស ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ និងថវិកាឧបត្ថម្ភពីថ្នាក់ជាតិដល់រាជធានី ខេត្ត និងក្រុង ស្រុក ស្មើនឹង០,២០% នៃផ.ស.ស ដែលក្នុងនោះថវិកាដែលត្រូវផ្ទេរសម្រាប់មូលនិធិក្រុង ស្រុកសម្រាប់ឆ្នាំ២០១៤ ត្រូវបានកំណត់ស្មើនឹង ០,៨% នៃចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ២០១៣។

ថ្នាក់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវដំណើរការរៀបចំគម្រោងចំណាយថវិកាដោយផ្អែកលើគោលការណ៍ដូចខាងក្រោម ៖

- ត្រូវស្ថិតក្នុងក្របខ័ណ្ឌដែលលទ្ធភាពសរុបចំណូលអាចធានាគាំទ្របានបាន
- ត្រូវបានរៀបចំដោយវិចារណកម្មទៅតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាដែលមានការពាក់ព័ន្ធ
- ត្រូវលម្អិតទៅតាមជំពូក គណនី និងអនុគណនីស្របតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាដែលមានការពាក់ព័ន្ធនិងទៅតាមលំដាប់លំដោយនៃអាទិភាពចំណាយ។

ខ-១- គម្រោងចំណាយរបស់រដ្ឋបាលរាជធានី ខេត្ត

ក្របខណ្ឌថវិកាបានគ្រោងចំណូល-ចំណាយថ្នាក់ក្រោមជាតិជារួម ឲ្យមានតុល្យភាព ដោយពុំមានការចាំបាច់ក្នុងការឧបត្ថម្ភពីថ្នាក់ជាតិ ដល់រាជធានី ខេត្តទេ។ ទោះជាយ៉ាងណាក្តី យើងនៅមានបញ្ហាប្រឈមមួយគឺការផ្ទេរធនធានពីខេត្តមានអតិរេក ទៅខេត្តឱនភាព គឺជាការលំបាក។ ដើម្បីដោះស្រាយបញ្ហានេះ ថវិការាជធានី ខេត្តនីមួយៗ មិនអាចមានកំណើនស្មើគ្នាបានឡើយ ដោយខេត្តមានចំណូលខ្ពស់ដូចជារាជធានីភ្នំពេញ ឬខេត្តសៀមរាប គួរត្រូវបានអនុញ្ញាតឲ្យបង្កើនចំណាយលើសពីកំណើនមធ្យមភាគ ២១,២%។ ដោយឡែក ខេត្តមានចំណូលទាបអនុញ្ញាតឲ្យមានកំណើនទាបជាង ព្រោះត្រូវបានឧបត្ថម្ភថវិកាពីថ្នាក់ជាតិ។

ខ-១-១- គម្រោងចំណាយរបស់រដ្ឋបាលរាជធានីត្រូវបានរៀបចំលម្អិតតាមជំពូក គណនី និងអនុគណនីស្របតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ដែលមានការពាក់ព័ន្ធដោយផ្អែកលើមូលដ្ឋានសរុបចំណូលក្រោយពីបានដកចេញនូវកញ្ចប់ថវិកាខណ្ឌនិងកញ្ចប់ថវិកាសង្កាត់ចំណុះរាជធានីរួចហើយ នឹងត្រូវបានបូកបញ្ចូលជាមួយគម្រោងចំណាយរបស់រដ្ឋបាលខណ្ឌនិងសង្កាត់ក្រោយពេលដែលរដ្ឋបាលខណ្ឌ និងសង្កាត់បានផ្ញើជូននូវគម្រោងថវិកាដែលក្រុមប្រឹក្សារបស់ខ្លួនបានអនុម័តរួច។

ខ-១-២- គម្រោងចំណាយរបស់រដ្ឋបាលខេត្ត ត្រូវបានរៀបចំលម្អិតតាមជំពូក គណនី និងអនុគណនីស្របតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ដែលមានការពាក់ព័ន្ធដោយផ្អែកលើគម្រោងចំណូលសរុបដែលបានគណនារួច។

ខ-២- គម្រោងចំណាយរបស់រដ្ឋបាល ក្រុង ស្រុក ខណ្ឌ

ខ-២-១- គម្រោងចំណាយរបស់រដ្ឋបាល ក្រុង ត្រូវបានរៀបចំលម្អិតទៅតាមជំពូក គណនី និងអនុគណនី ស្រប

p

តាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ដែលមានការពាក់ព័ន្ធដោយផ្អែកលើមូលដ្ឋានសរុបចំណូល ក្រោយពីបានដកចេញនូវកញ្ចប់ថវិកាសង្កាត់ចំណុះក្រុងរួចហើយ និងត្រូវធ្វើការបូកបញ្ចូលជាមួយគម្រោងចំណាយរបស់រដ្ឋបាលសង្កាត់ក្រោយពេលដែលសង្កាត់ចំណុះក្រុង បានផ្ញើជូនគម្រោងថវិកាដែលក្រុមប្រឹក្សារបស់ខ្លួនបានអនុម័តរួច។

ខ-២-២- គម្រោងចំណាយរបស់រដ្ឋបាល ស្រុក ត្រូវបានរៀបចំលម្អិតទៅតាមជំពូក គណនី និង អនុគណនី ស្របតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាដែលមានការពាក់ព័ន្ធដោយផ្អែកលើមូលដ្ឋានសរុបចំណូលដែលបានគណនារួច។

ខ-២-៣- គម្រោងចំណាយរបស់រដ្ឋបាល ខណ្ឌ ត្រូវបានរៀបចំលម្អិតទៅតាមជំពូក គណនី និងអនុគណនី ស្របតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាដែលមានការពាក់ព័ន្ធ ដោយផ្អែកលើមូលដ្ឋានកញ្ចប់ថវិកាដែលរដ្ឋបាលរាជធានីបានជូនដំណឹង។

ខ-៣- គម្រោងចំណាយរបស់រដ្ឋបាលឃុំ សង្កាត់

ខ-៣-១- គម្រោងចំណាយរបស់រដ្ឋបាល ឃុំ ត្រូវបានរៀបចំលម្អិតទៅតាមជំពូក គណនី និងអនុគណនីស្របតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាដោយផ្អែកលើមូលដ្ឋានសរុបចំណូលដែលបានគណនារួច។

ខ-៣-២- គម្រោងចំណាយរបស់រដ្ឋបាល សង្កាត់ ត្រូវបានរៀបចំលម្អិតទៅតាមជំពូក គណនី និងអនុគណនី ស្របតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាដែលមានការពាក់ព័ន្ធដោយផ្អែកលើមូលដ្ឋានកញ្ចប់ថវិកាដែលរដ្ឋបាលរាជធានី និងរដ្ឋបាលក្រុងបានជូនដំណឹង។

គ- ការរៀបចំគម្រោងចំណាយ

ចំណាយទាំងអស់ត្រូវតែមានការវិភាគ និងមានលិខិតយុត្តិការភ្ជាប់មកជាមួយតាមជំពូក គណនី អនុគណនី ដើម្បីបង្ហាញឲ្យឃើញថាការគិតគូរចំណាយរបស់ខ្លួនមានភាពត្រឹមត្រូវហ្មត់ចត់ និងសមហេតុផល ហើយលិខិតយុត្តិការទាំងអស់នេះ ទុកសម្រាប់ធ្វើជាមូលដ្ឋានលើការពិនិត្យនីត្យានុកូលភាពនៃថវិកា។

គ-១- ការរៀបចំគម្រោងចំណាយចរន្ត

គ-១-១- ប្រភេទ ១ ៖ មធ្យោបាយសេវា

គ-១-១-១- ជំពូក ៦២ និង ៦៤ សេវាខាងក្រៅផ្សេងៗនិងបន្ទុកបុគ្គលិក

ចំណាយសម្រាប់បុគ្គលិកត្រូវតែ គិតគូរឲ្យបានច្បាស់លាស់។ ចំណាយលើជំពូក ៦៤ ត្រូវបានចាត់ទុកជាចំណាយដែលមានអាទិភាពបំផុតក្នុងការរៀបចំគម្រោងថវិកា។

ចំណាយបុគ្គលិក (ជំពូក ៦៤) ត្រូវគ្រោងទៅតាមតារាងប្រព័ន្ធប្រាក់បៀវត្សនៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈ និងតាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងក្នុងឆ្នាំ២០១៣។ រាជរដ្ឋាភិបាលបាន

p

គ្រោងកញ្ចប់ថវិកាមួយសម្រាប់ដំឡើងបៀវត្សឆ្នាំ២០១៤ ប៉ុន្តែដោយសាររាជរដ្ឋាភិបាលកំពុងរៀបចំក្របខ័ណ្ឌ និងយុទ្ធសាស្ត្រសម្រាប់ការដំឡើងប្រកបដោយសមធម៌ សង្គតិភាព និងប្រសិទ្ធភាព ជាពិសេសដើម្បីធានាឲ្យមានគំលាតសមស្របរវាងអ្នកមានបៀវត្សខ្ពស់ និងទាប ព្រមទាំងធានាស្ថេរភាព និងចីរភាពថវិកា ក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈ និងម៉ាក្រូសេដ្ឋកិច្ចគ្រប់ក្រសួងស្ថាប័ន ត្រូវគ្រោងទៅតាមមូលដ្ឋាននៃក្របខ័ណ្ឌបៀវត្សបច្ចុប្បន្នសិន នៅពេលដែលក្របខ័ណ្ឌ និងយុទ្ធសាស្ត្រនៃការអនុវត្តប្រព័ន្ធបៀវត្សថ្មីត្រូវបានអនុម័ត រាជរដ្ឋាភិបាលនឹងបំពេញបន្ថែមនូវថវិកាសម្រាប់ការអនុវត្តតាមក្របខ័ណ្ឌថ្មីនៃប្រព័ន្ធបៀវត្ស ដល់គ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ចំពោះមន្ត្រីរាជការដែលត្រូវជ្រើសរើសបន្ថែមថ្មី ត្រូវគ្រោងដោយផ្អែកលើសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល និងតាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងមានទិដ្ឋាការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬលាឈប់ពីក្របខ័ណ្ឌរដ្ឋ និងមរណៈភាពត្រូវកាត់ចេញពីអង្គភាពរបស់ខ្លួន និងមិនត្រូវគ្រោងទេ។ ចំពោះការឡើងឋានៈ និងកាំប្រាក់ត្រូវគ្រោងដោយឡែក និងដោយផ្អែកលើលិខិតយុត្តិការផ្លូវការរបស់រាជរដ្ឋាភិបាល។ មិនត្រូវគិតអតិផរណានៅក្នុងការគ្រោងចំណាយបៀវត្សនេះទេ។

ការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំចំនួនមន្ត្រីរាជការ ពលករអណ្តែតនិងមន្ត្រីជាប់កិច្ចសន្យាដែលកំពុងបំពេញការងារនៅតាមរដ្ឋបាលក្រុង ស្រុក ខណ្ឌ នីមួយៗដែលរួមទាំងមន្ត្រីស្មៀនឃុំ ផងនោះ ហើយបានអនុវត្តតាមគំរូតារាងដែលមានខ្លឹមសារដូចនឹងតារាងប្រាក់បៀវត្សរបស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំមុនត្រូវបន្តអនុវត្តទៀត ដើម្បីដាក់ជូនអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ចុះហត្ថលេខាបោះត្រាបញ្ជាក់។ ចំពោះចំនួនមន្ត្រីរាជការបន្ថែមថ្មីត្រូវគ្រោងដោយផ្អែកលើសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលតាមសំណើរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងមានទិដ្ឋាការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬលាឈប់ពីក្របខ័ណ្ឌរដ្ឋ និងមរណៈភាពត្រូវកាត់ចេញពីអង្គភាពរបស់ខ្លួន។

ចំពោះប្រាក់បំណាច់មុខងារអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រោងនៅក្នុងអនុគណនី ៦៤១១ ប្រាក់បំណាច់មុខងារអភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រោងនៅក្នុងអនុគណនី ៦៤១២និងប្រាក់បំណាច់មុខងារមន្ត្រីរាជការត្រូវគ្រោងក្នុងអនុគណនី៦៤២២។ ចំពោះប្រាក់បៀវត្សមូលដ្ឋានរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ត្រីរាជការត្រូវគ្រោងនៅក្នុងអនុគណនី ៦៤២១។

ចំពោះគម្រោងប្រាក់ឧបត្ថម្ភរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងមន្ត្រីភូមិត្រូវគ្រោងនៅក្នុងជំពូក៦៤ គណនី៦៤៤ (លាភការផ្សេងៗទៀតបុគ្គលិកមិនមែនក្របខណ្ឌអនុគណនី ៦៤៤២ ប្រាក់ឧបត្ថម្ភក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអនុគណនី៦៤៤៥ ប្រាក់ឧបត្ថម្ភមន្ត្រីភូមិ) ប្រាក់ឧបត្ថម្ភចំពោះសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានកំណត់តាមអនុក្រឹត្យលេខ ២១៤ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩។ ចំពោះប្រាក់បំណាច់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រាក់ឧបត្ថម្ភមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ ត្រូវគ្រោងបង្កើនមួយរយភាគរយ។

p

ក្នុងករណីដែលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានតម្រូវការអំពីពលករអណ្តែតត្រូវគ្រោងនៅក្នុងជំពូក៦៤ គណនី៦៤៤ អនុគណនី៦៤៤៣ (បៀវត្សមូលដ្ឋាន បុគ្គលិកអណ្តែត) និងមន្ត្រីជាប់កិច្ចសន្យាការងារឯកទេសដែលត្រូវចុះកិច្ចសន្យាអនុវត្តសម្រាប់រយៈពេលខ្លីជាកំណត់ត្រូវគ្រោងនៅក្នុងជំពូក៦៤ គណនី៦៤៤ អនុគណនី៦៤៤១ (បៀវត្សមូលដ្ឋានបុគ្គលិកមិនមែនក្របខណ្ឌ)។

ចំនួនបុគ្គលិកទាំងអស់ ដែលស្ថិតនៅក្រោមឱវាទរបស់ថ្នាក់រដ្ឋបាលនីមួយៗត្រូវបូកសរុបនៅក្នុងតារាងទី១ និងចំនួនក្រុមប្រឹក្សាទាំងអស់ត្រូវបូកសរុបនៅក្នុងតារាងទី១«ក» ដែលបានភ្ជាប់ជូនមកជាមួយនេះ។ សលាកប័ត្រនេះមានចែកជាច្រើនខ្ទង់សម្រាប់កត់ត្រានូវប្រភេទបុគ្គលិកទាំងអស់ដែលថ្នាក់រដ្ឋបាលនីមួយៗមាន។

បុគ្គលិក មន្ត្រីរាជការដែលលម្អិតទៅតាមអង្គភាពនីមួយៗ ហើយចំនួននេះត្រូវតែផ្ទៀងផ្ទាត់ជាមួយនិងចំនួនដែលមាននៅក្នុងតារាងសរុបចំណាយ (តាមតារាងប្រព័ន្ធប្រាក់បៀវត្សរបស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល)។

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវលម្អិតចំនួនបុគ្គលិកទៅតាមរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនីមួយៗដែលស្ថិតនៅក្រោមឱវាទរបស់ខ្លួន។

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សង្កាត់ ត្រូវគ្រោងលម្អិតជំពូក៦២ សេវាខាងក្រៅផ្សេងៗទៀតនៅក្នុងតារាងទី២ ដូចជាចំណាយទទួលភ្ញៀវ បេសកកម្ម ទូរស័ព្ទ ពិធីបុណ្យផ្សេងៗ គណៈបញ្ជាការឯកភាព.......។

ឥ-១-១-២- ជំពូក ៦០ និង ៦១ (ការទិញ សេវាខាងក្រៅ)

ប្រមូលផ្តុំរាល់ការចំណាយដំណើរការរដ្ឋបាល ទិញសម្ភារៈ ជួសជុលតូច និងចំណាយជាគុណប្រយោជន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវគ្រោងនៅក្នុងតារាងទី៣ និងតារាងទី៤។ ឥណទានចំណាយក្នុងជំពូកនេះ ចែកចេញជាពីរផ្នែកសំខាន់ៗ ៖

មួយផ្នែកជាឥណទានសម្រាប់បម្រើឲ្យកិច្ចប្រតិបត្តិការរដ្ឋបាលសុទ្ធសាធ ដែលចាំបាច់ត្រូវគិតគូរឲ្យបានហ្មត់ចត់ និងត្បិតត្បៀតសន្សំសំចៃ ដោយផ្អែកលើគោលការណ៍រួមរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងចំណាយសាធារណៈ។ ក្នុងឆ្នាំ២០១៤ឥណទានចំណាយផ្នែកនេះគឺអនុញ្ញាតឲ្យគ្រោងក្នុងកំរិតប្រហាក់ប្រហែលនឹងឆ្នាំ២០១៣ តែប៉ុណ្ណោះ។

ដោយឡែកថ្លៃឈ្នួល និងបន្ទុក (គណនី ៦១៣) គឺអនុញ្ញាតឲ្យគ្រោងតែចំណាយសម្រាប់ជួលស្នាក់ការរដ្ឋបាលតែប៉ុណ្ណោះ។

មួយផ្នែកទៀតជាឥណទានសម្រាប់បម្រើដល់គុណប្រយោជន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការរៀបចំមូលដ្ឋានសម្ភារៈនៃសេវាសាធារណៈនិងការអភិវឌ្ឍ។ ផ្អែកលើផែនការយុទ្ធសាស្ត្រនិងផែនការអភិវឌ្ឍថ្នាក់រដ្ឋបាលនីមួយៗ ចាំបាច់ត្រូវរៀបចំទៅតាមលំដាប់លំដោយនៃអាទិភាពរបស់គម្រោងចំណាយអំពីការងារគុណប្រយោជន៍របស់ខ្លួន។

ទន្ទឹមនោះ ថ្នាក់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវយកចិត្តទុកដាក់បង្កើននូវចំណាយអភិវឌ្ឍ ក្នុងករណីដែលលទ្ធភាពចំណូលសម្រេចបានលើសផែនការ ព្រោះការអភិវឌ្ឍនៅមូលដ្ឋានគឺជាគោលបំណងនៃគោលនយោបាយនិងជាទិសដៅយុទ្ធសាស្ត្រអាទិភាពខ្ពស់បំផុតរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

p

អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ត្រូវគ្រោងឥណទានសម្រាប់ចំណាយជាគុណប្រយោជន៍រាជធានី ខេត្ត ក្រុង ស្រុកតាមការងារនីមួយៗ (បំភ្លឺសាធារណៈ ប្រមូលសំរាម អនាម័យ សន្តិសុខ ប្រឆាំងអគ្គិភ័យ ការផ្គត់ផ្គង់ទឹក....) និងតាមការដ្ឋាននីមួយៗ (ផ្លូវថ្នល់ ស្ពាន សួនច្បារ លូទឹក ប្រឡាយ...) ដោយមានបញ្ជាក់អំពីបញ្ជីប៉ាន់តម្លៃ និងទីតាំងច្បាស់លាស់ដែលជាឯកសារសម្រាប់ការពិភាក្សាថវិកាប្រចាំឆ្នាំ។

ជាទូទៅចំណាយដំណើរការរដ្ឋបាល ទិញសម្ភារៈ ការថែទាំ និងការជួសជុលតូច ត្រូវគិតគូរទៅតាមតម្រូវការនៃកម្មវិធីសកម្មភាពឬទៅតាមបទដ្ឋានសមស្រប។ ម្យ៉ាងទៀតរាជធានី ខេត្ត ក្រុង ស្រុក មិនត្រូវគ្រោងបំប៉ោងឥណទានដែលស្នើសុំសម្រាប់ចំណាយប្រភេទនេះទេ។ ឥណទានសម្រាប់ចំណាយរដ្ឋបាលអចិន្ត្រៃយ៍ ដូចជា ទូរស័ព្ទ អគ្គិសនី ទឹក សម្ភារៈការិយាល័យ ប្រេងឥន្ធនៈ និងការទទួលភ្ញៀវត្រូវគិតគូរក្នុងកំរិតប្រហាក់ប្រហែលនិងឆ្នាំ២០១៣ និងត្រូវគ្រប់គ្រងយ៉ាងម៉ឺងម៉ាត់ ដើម្បីសន្សំសំចៃលើចំណាយប្រភេទនេះ ជាពិសេសឥណទានសម្រាប់ចំណាយអគ្គិសនី ទឹក សម្រាប់គុណប្រយោជន៍របស់រាជធានី ខេត្ត ក្រុង ស្រុក ត្រូវគ្រោងឲ្យបានគ្រប់គ្រាន់សម្រាប់តម្រូវការក្នុងឆ្នាំ និងការសងបំណុល។ ក្នុងករណីដែលរាជធានី ខេត្ត ក្រុង ស្រុក គ្រោងមិនបានគ្រប់គ្រាន់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុនឹងធ្វើនិយ័តកាពឥណទានផ្ទៃក្នុងជំពូកថវិកាបេស់រាជធានី ខេត្ត ក្រុង ស្រុក ហើយដាក់កម្មវិធីចំណាយសម្រាប់ទូទាត់ជូនរាជធានី ខេត្ត ក្រុង ស្រុកដោយស្វ័យប្រវត្តិ។ ចំពោះគម្រោងថវិការបស់រដ្ឋបាលក្រុង ស្រុក រៀបចំមិនត្រឹមត្រូវតាមគោលការណ៍ណែនាំខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងធ្វើការកែតម្រូវថវិការបស់រដ្ឋបាលក្រុង ស្រុក ឡើងវិញឲ្យសមស្របតាមសារាចរណែនាំនេះ។

គ-១-២- ប្រភេទ ៣ : ចំណាយអន្តរាគមន៍សាធារណៈ

គ-១-២-១- ជំពូក ៦៥ : ការឧបត្ថម្ភធន និងជំនួយសង្គម

ចំណាយប្រភេទនេះត្រូវចែងលម្អិតឲ្យច្បាស់លាស់នូវគោលដៅដែលត្រូវសម្រេច។ ត្រូវពិនិត្យជ្រើសរើសចំណាយប្រភេទនេះឲ្យបានហ្មត់ចត់ដោយផ្អែកលើលក្ខណៈសម្បត្តិនៃអ្នកដែលទទួលផល និងចំនួនទឹកប្រាក់ដែលត្រូវពិនិត្យផ្តល់ជូន(គម្រោងចំណាយនេះត្រូវសរុបតារាងទី៥)។

គ-១-៣-ប្រភេទ៤ : ចំណាយផ្សេងៗ

គ-១-៣-១- ជំពូក ៦៣ : (ពន្ធ និងអាករ)

ចំណាយប្រភេទនេះ គឺសម្រាប់កាតព្វកិច្ចពន្ធដូចជាចំណាយលើអាករ (លតាប័ត្រលើរថយន្ត ម៉ូតូរបស់រដ្ឋ.......) ពន្ធប្រថាប់ត្រាសម្រាប់ទទួលកម្មសិទ្ធិ និងចំណាយបង់ពន្ធអាករផ្សេងៗទៀតតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (គម្រោងចំណាយនេះត្រូវសរុបតារាងទី៦)។

គ-១-៤- ប្រភេទ ៦ : ចំណាយមិនបានគ្រោងទុក

គ-១-៤-១- ជំពូក ០៩ : (ចំណាយមិនបានគ្រោងទុក)

ចំណាយប្រភេទនេះ គឺជាការគិតគូរគ្រោងបម្រុងសម្រាប់ចំណាយចៃដន្យ ដែលអាចកើតមានជាយថាហេតុនៅក្នុងឆ្នាំអនុវត្ត។ សម្រាប់ឆ្នាំថវិកា២០១៤ ប្រភេទឥណទាននេះ គឺអនុញ្ញាតឲ្យគ្រោងពី៣ទៅ៥ភាគរយនៃ

p

គម្រោងចំណាយសរុបរបស់ថ្នាក់រដ្ឋបាលនីមួយៗ ហើយខ្ទង់ចំណាយនេះ ពេលអនុវត្តត្រូវស្នើសុំធ្វើនិយ័តភាពទៅបំពេញឲ្យជំពូកដទៃទៀតដែលតម្រូវការចំណាយចៃដន្យកើតមានឡើងជាយថាហេតុ និងតម្រូវការចំណាយសម្រាប់អភិវឌ្ឍរាជធានី ខេត្ត ក្រុង ស្រុក។

គ-២- ការរៀបចំគម្រោងចំណាយជាមូលធន:

គ-២-១- ប្រភេទ ២ : អចលកម្ម

គ-២-១-១- ជំពូក ២០ និងជំពូក ២១ : (អចលកម្មអរូបី និងអចលកម្មរូបី)

ចំណាយជាមូលធន គឺជាចំណាយសម្រាប់ធ្វើហិរញ្ញប្បទានចំពោះគម្រោងវិនិយោគដែលមានការព្រមព្រៀងគ្នាជាមុន និងសំដៅធ្វើឲ្យសម្រេចតាមគោលដៅដែលបានដាក់ចេញ។

គម្រោងវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិអាចគ្រោងបានក្នុងករណីដែលរដ្ឋបាលថ្នាក់ក្រោមជាតិបានទទួលគោលការណ៍អនុញ្ញាតជាផ្លូវការឲ្យគ្រប់គ្រងហិរញ្ញប្បទានដោយផ្ទាល់។

ការវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេសដោយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិអាចគ្រោងបានក្នុងករណីដែលរដ្ឋបាលថ្នាក់ក្រោមជាតិមានអតិរេកចរន្តឬមានចំណូលជាមូលធនផ្ទៃក្នុងដោយផ្ទាល់ (គម្រោងចំណាយនេះត្រូវសរុបក្នុងតារាងទី៧)។

ការវិនិយោគដោយហិរញ្ញប្បទានពីបរទេសផ្ទាល់ត្រូវផ្អែកលើកម្មវិធីជំនួយឬគម្រោងការដែលអង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ឬម្ចាស់ជំនួយទ្វេភាគីមានបំណងផ្តល់ត្រង់ទៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានកត់ត្រាចូលទៅក្នុងគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ទន្ទឹមនឹងនេះរដ្ឋបាលថ្នាក់ក្រោមជាតិក៏ត្រូវយកចិត្តទុកដាក់ផងដែរក្នុងការកត់ត្រារាល់ចំណាយថវិកាបដិភាគជាប្រាក់រៀលដែលត្រូវអនុវត្តជាមួយគម្រោងដោយហិរញ្ញប្បទានពីបរទេសផ្ទាល់។

គម្រោងវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលបញ្ចូលទៅក្នុងគម្រោងថវិកាប្រចាំឆ្នាំគឺ ត្រូវផ្អែកលើកម្មវិធីវិនិយោគដែលបានធ្វើបច្ចុប្បន្នភាពនិងត្រូវបានក្រុមប្រឹក្សាពិនិត្យអនុម័តចុងក្រោយគេបំផុត។

ឃ- វិធីសាស្ត្រក្នុងការរៀបចំគម្រោងចំណូលចំណាយថវិកា

គម្រោងចំណូល ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំឡើងក្រោមការទទួលខុសត្រូវរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នឹងមេឃុំ ចៅសង្កាត់ ហើយត្រូវបានពិនិត្យនិងអនុម័តដោយក្រុមប្រឹក្សានៃថ្នាក់រដ្ឋបាលនីមួយៗ។

ឃ-១- ការរៀបចំគម្រោងចំណូល

ឃ-១-១- នៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវអញ្ជើញប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រធានសាខាពន្ធដារ ប្រធានមន្ទីរជំនាញ និងអង្គភាពដែលមានការពាក់ព័ន្ធក្នុងការប្រមូលចំណូលសារពើពន្ធនិងចំណូលមិនមែនសារពើពន្ធមកពិភាក្សាគិតគូររៀបចំដើម្បីកំណត់ឲ្យបាននូវគម្រោង

p

សរុបចំណូលថវិកាប្រចាំឆ្នាំ២០១៤។ ចំពោះសាលារាជធានី ត្រូវមានការអញ្ជើញចូលរួមពីអភិបាលនៃគណៈអភិបាលខណ្ឌ និងចៅសង្កាត់ទាំងអស់ចំណុះរាជធានីដើម្បីលើកឡើងអំពីលទ្ធភាពប្រមូលចំណូលមិនមែនសារពើពន្ធនៅមូលដ្ឋាន និងចំណូលដែលសង្កាត់ចំណុះរាជធានីទទួលបានពីការវិភាជន៍មូលនិធិឃុំ សង្កាត់ ។

ឃ-១-២- នៅថ្នាក់ក្រុង ស្រុក អភិបាលនៃគណៈអភិបាលក្រុង ស្រុកដោយមានជំនួយពីប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ និងប្រធានការិយាល័យច្រកចេញចូលតែមួយត្រូវព្យាករណ៍នូវលទ្ធភាពប្រមូលចំណូលមិនមែនសារពើពន្ធនៅមូលដ្ឋានបូករួមជាមួយចំណូលដែលទទួលបានពីការវិភាជន៍មូលនិធិក្រុង ស្រុក ដើម្បីកំណត់នូវកញ្ចប់គម្រោងសរុបចំណូលថវិកាប្រចាំឆ្នាំ២០១៤ របស់សាលាក្រុង ស្រុកផ្ទាល់។

ដោយឡែកចំពោះរដ្ឋបាលក្រុង ត្រូវមានការអញ្ជើញចូលរួមពីចៅសង្កាត់ទាំងអស់ចំណុះក្រុង ដើម្បីលើកឡើងអំពីលទ្ធភាពប្រមូលចំណូលមិនមែនសារពើពន្ធនៅមូលដ្ឋាន និងចំណូលដែលសង្កាត់ចំណុះក្រុងទទួលបានពីការវិភាជន៍មូលនិធិឃុំ សង្កាត់ឆ្នាំ២០១៤។

ឃ-១-៣- នៅថ្នាក់រដ្ឋបាលខណ្ឌ អភិបាលនៃគណៈអភិបាលខណ្ឌដោយមានជំនួយពីប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ និងប្រធានការិយាល័យច្រកចេញចូលតែមួយ(បើមាន) ត្រូវព្យាករណ៍លទ្ធភាពប្រមូលចំណូលមិនមែនសារពើពន្ធនៅមូលដ្ឋានប្រចាំឆ្នាំ ដើម្បីរាយការណ៍នៅពេលទៅចូលរួមប្រជុំរៀបចំគម្រោងចំណូលប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី។

ឃ-១-៤- នៅថ្នាក់រដ្ឋបាលឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ត្រូវព្យាករណ៍អំពីលទ្ធភាពប្រមូលចំណូលមិនមែនសារពើពន្ធនៅមូលដ្ឋានបូករួមជាមួយចំណូលដែលទទួលបានការវិភាជន៍មូលនិធិឃុំ សង្កាត់ ដើម្បីកំណត់ឲ្យបាននូវកញ្ចប់គម្រោងសរុបចំណូលថវិកាប្រចាំឆ្នាំ។ ដោយឡែកចៅសង្កាត់ត្រូវរាយការណ៍អំពីគម្រោងសរុបចំណូលថវិកាប្រចាំឆ្នាំរបស់ខ្លួននៅពេលទៅចូលរួម រៀបចំគម្រោងចំណូលប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី និងក្រុង។

ឃ-២- ការរៀបចំគម្រោងចំណាយ

ឃ-២-១- នៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវរៀបចំប្រជុំដោយមានការចូលរួមពីនាយករដ្ឋបាល នាយកទីចាត់ការហិរញ្ញវត្ថុ និងមន្ត្រីជំនាញដែលទទួលបន្ទុករៀបចំគម្រោងចំណាយ ដើម្បីពិភាក្សា គណនាអំពីតម្រូវការ និងលំដាប់លំដោយនៃអាទិភាពចំណាយទាំងអស់ដើម្បីរៀបចំគម្រោងចំណាយដោយដាក់បញ្ចូលឲ្យបានត្រឹមត្រូវតាមខ្លឹមសារចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា។

ដោយឡែកគម្រោងចំណាយរបស់រដ្ឋបាលរាជធានីត្រូវបូកបញ្ចូលនូវគម្រោងចំណាយរបស់រដ្ឋបាលខណ្ឌ និងសង្កាត់ទាំងអស់ចំណុះរាជធានី ក្រោយពេលដែលរដ្ឋបាលខណ្ឌ និងសង្កាត់ទាំងនោះបានផ្ញើជូននូវគម្រោងថវិកាដែលក្រុមប្រឹក្សារបស់ខ្លួនបានអនុម័តរួច។

ឃ-២-២- នៅថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំការប្រជុំដោយមានការចូលរួមពីនាយករដ្ឋបាល ប្រធានការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ និងមន្ត្រីជំនាញដែលទទួល

p

បន្ទុករៀបចំគម្រោងចំណាយដើម្បីពិភាក្សា គណនាអំពីតម្រូវការ និងលំដាប់លំដោយនៃអាទិភាពចំណាយទាំងអស់ក្នុងការរៀបចំគម្រោងចំណាយដោយដាក់បញ្ចូលឲ្យបានត្រឹមត្រូវតាមខ្លឹមសារ ចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា។

ដោយឡែកគម្រោងចំណាយរបស់រដ្ឋបាលក្រុង ត្រូវបូកបញ្ចូលនូវគម្រោងចំណាយរបស់រដ្ឋបាលសង្កាត់ទាំងអស់ចំណុះរដ្ឋបាលក្រុង ក្រោយពេលដែលរដ្ឋបាលសង្កាត់ទាំងនោះបានផ្ញើជូននូវគម្រោងថវិកាដែលក្រុមប្រឹក្សារបស់ខ្លួនបានអនុម័តរួច។

ឃ-២-៣- នៅថ្នាក់រដ្ឋបាលឃុំ សង្កាត់ មេឃុំ និងចៅសង្កាត់ត្រូវរៀបចំប្រជុំដោយមានការចូលរួមពីស្មៀន និងមន្ត្រីជំនាញ (បើមាន) ពិភាក្សាអំពីតម្រូវការ និងលំដាប់លំដោយអាទិភាពនៃចំណាយទាំងអស់ដើម្បីរៀបចំគម្រោងចំណាយដោយដាក់បញ្ចូលឲ្យបានត្រឹមត្រូវតាមខ្លឹមសារ ចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា។

ង- កាលបរិច្ឆេទនៃការរៀបចំនិងអនុម័តគម្រោងថវិកា

នៅសប្ដាហ៍ទី១ នៃខែមិថុនា ឆ្នាំ២០១៣ នាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋានត្រូវជូនដំណឹងអំពីថវិកាឧបត្ថម្ភដែលត្រូវផ្ទេរពីថវិកាជាតិទៅថ្នាក់នីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ(មូលនិធិឧបត្ថម្ភគធនរាជធានី ខេត្ត ក្រុង ស្រុកនិងមូលនិធិឃុំ សង្កាត់) ដើម្បីរៀបចំគម្រោងថវិការបស់ខ្លួន។

ង-១- នៅថ្នាក់រដ្ឋបាលឃុំ មេឃុំនីមួយៗក្រោយពីទទួលបានចំណូលពីការវិភាជន៍មូលនិធិឃុំ សង្កាត់និងលទ្ធភាពចំណូលដែលអាចប្រមូលបាននៅនឹងមូលដ្ឋាន ត្រូវដំណើរការរៀបចំគម្រោងថវិកា និងដាក់ជូនក្រុមប្រឹក្សារបស់ខ្លួនពិនិត្យនិងអនុម័ត យ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៣។

ង-២- នៅរដ្ឋបាលថ្នាក់សង្កាត់ ចៅសង្កាត់នីមួយៗក្រោយពីទទួលបានកញ្ចប់ថវិកា(សរុបចំណូល)ពីរដ្ឋបាលរាជធានី និងរដ្ឋបាលក្រុង ត្រូវដំណើរការរៀបចំគម្រោងថវិការួចដាក់ជូនក្រុមប្រឹក្សារបស់ខ្លួនពិនិត្យនិងអនុម័ត យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ហើយផ្ញើទៅរដ្ឋបាលរាជធានី និងរដ្ឋបាលក្រុង យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣។

ង-៣- នៅថ្នាក់រដ្ឋបាលក្រុង ស្រុក អភិបាលនៃគណៈអភិបាលក្រុង ស្រុក ក្រោយពីបានទទួលចំណូលពីការវិភាជន៍មូលនិធិក្រុង ស្រុក និងលទ្ធភាពចំណូលដែលអាចប្រមូលបាននៅមូលដ្ឋាន ត្រូវដំណើរការរៀបចំគម្រោងថវិកា និងដាក់ជូនក្រុមប្រឹក្សារបស់ខ្លួនពិនិត្យ និងអនុម័តយ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៣។ ចំពោះគម្រោងថវិការបស់រដ្ឋបាលក្រុង ត្រូវបូកបញ្ចូលគម្រោងថវិការបស់រដ្ឋបាលសង្កាត់ទាំងអស់ចំណុះរដ្ឋបាលក្រុង។ អភិបាលនៃគណៈអភិបាលក្រុង ត្រូវបែងចែកនិងជូនដំណឹងអំពីកញ្ចប់ថវិកាដល់រដ្ឋបាលសង្កាត់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៣ និងជួយគាំទ្រឲ្យរដ្ឋបាលសង្កាត់រៀបចំគម្រោងថវិកា ដើម្បីដាក់ឆ្លងក្រុមប្រឹក្សារបស់ខ្លួនយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣។

p

ខ-៤- នៅថ្នាក់រដ្ឋបាលខណ្ឌ អភិបាលនៃគណៈអភិបាលខណ្ឌ ក្រោយពីបានទទួលកញ្ចប់ថវិកា(សរុបចំណូល) ពីរដ្ឋបាលរាជធានី ត្រូវដំណើរការរៀបចំគម្រោងថវិកានិងដាក់ជូនក្រុមប្រឹក្សារបស់ខ្លួនពិនិត្យនិងអនុម័ត យ៉ាងយឺតបំផុតត្រឹមថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ហើយផ្ញើទៅរដ្ឋបាលរាជធានីយ៉ាងយឺតបំផុតត្រឹមថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣។

ខ-៥- នៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រោយពីបានទទួលកញ្ចប់ថវិកាពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវព្យាករណ៍នូវលទ្ធភាពចំណូលសរុបទាំងអស់ ដើម្បីរៀបចំគម្រោងថវិកានិងដាក់ជូនក្រុមប្រឹក្សារបស់ខ្លួនពិនិត្យនិងអនុម័ត យ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៣។

ចំពោះគម្រោងថវិការបស់រដ្ឋបាលរាជធានីត្រូវបូកបញ្ចូលគម្រោងថវិការបស់រដ្ឋបាលខណ្ឌ និងសង្កាត់ទាំងអស់ចំណុះរដ្ឋបាលរាជធានី។ អភិបាលនៃគណៈអភិបាលរាជធានី ត្រូវបែងចែកនិងជូនដំណឹងអំពីកញ្ចប់ថវិកាដល់រដ្ឋបាលខណ្ឌនិងសង្កាត់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៣ និងត្រូវជួយគាំទ្រឲ្យរដ្ឋបាលខណ្ឌ សង្កាត់ រៀបចំគម្រោងថវិកា ដើម្បីដាក់ឆ្លងក្រុមប្រឹក្សារបស់ខ្លួនឲ្យបានយ៉ាងយឺតត្រឹមថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣។

ច- យន្តការគាំទ្រការរៀបចំគម្រោងថវិកា

ច-១- ឆ្នាំ២០១៤ គឺជាឆ្នាំដែលគ្រប់ថ្នាក់រដ្ឋបាលទាំងអស់នៅរដ្ឋបាលថ្នាក់ក្រោមជាតិមានថវិកាផ្ទាល់របស់ខ្លួន ហើយក៏ជាឆ្នាំដែលគ្រប់ថ្នាក់រដ្ឋបាលទាំងអស់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ រៀបចំគម្រោងថវិការបស់ខ្លួនទៅតាមទម្រង់និងចំណាត់ថ្នាក់នៃមាតិកាថវិកាឯកភាពមួយ ដើម្បីឆ្លើយតបទៅនឹងខ្លឹមសារនៃការអនុវត្តច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលតម្រូវឲ្យថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងមូលគឺជាកញ្ចប់មួយ និងដាក់បញ្ចូលជាជំពូកមួយនៃសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។

ច-២- នៅក្នុងដំណើរការរៀបចំនិងអនុវត្តថវិកាផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិទៅតាមចេតនាសម្ព័ន្ធនៃកំណែទម្រង់រដ្ឋបាលថ្មី ការចាំបាច់បំផុតគឺ តម្រូវឲ្យមានយន្តការគាំទ្រជាប្រចាំដល់ថ្នាក់រដ្ឋបាលទាំងអស់នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសនៅថ្នាក់រដ្ឋបាលឃុំ សង្កាត់។

ច-៣- មន្ត្រីអគ្គនាយកដ្ឋានរតនាគារជាតិ នាយកដ្ឋានលទ្ធកម្មសាធារណៈ និងនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចុះជាប្រចាំទៅចូលរួមជាជំនួយការឲ្យក្រុមការងារនៅថ្នាក់រាជធានី ខេត្ត ដើម្បីចល័តជួយគាំទ្រដល់ថ្នាក់ក្រុង ស្រុក ខណ្ឌ និងថ្នាក់ឃុំ សង្កាត់ ដែលជួបបញ្ហាក្នុងការរៀបចំគម្រោងថវិកាឆ្នាំ២០១៤។ ក្នុងករណីចាំបាច់ត្រូវសុំអន្តរាគមន៍ជាបន្ទាន់មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ច-៤- នៅថ្នាក់រាជធានី ខេត្ត អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ត្រូវចេញសេចក្តីសម្រេចបង្កើតក្រុមការងារដែលមានប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាប្រធាន ប្រធានរតនាគារជាអនុប្រធាន និងនាយកទីចាត់

ការហិរញ្ញវត្ថុសាលារាជធានី ខេត្តជាសមាជិក ដើម្បីគាំទ្រជាប្រចាំដល់ថ្នាក់រដ្ឋបាលនីមួយៗក្នុងការរៀបចំ និង អនុវត្តថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្រុមការងារនេះដោយមានជំនួយការពីមន្ត្រីនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវប្រមូលផ្តុំមេឃុំ និងចៅសង្កាត់នៅថ្នាក់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីពន្យល់ណែនាំអំពីរបៀបរៀបចំគម្រោងថវិកាឆ្នាំ២០១៤ ទៅតាមទម្រង់និងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាឯកភាពតែមួយ។

ទទួលបានសារាចរណែនាំនេះ គ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវសហការគ្នាជួយគាំទ្រឲ្យការរៀបចំគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិឆ្នាំ២០១៤ សម្រេចបានដោយជោគជ័យ។

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

កន្លែងទទួល:

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ

«ដើម្បីជូនជ្រាប»

- អគ្គនាយកដ្ឋានរតនាគារជាតិ
- គ្រប់សាលារាជធានី ខេត្ត
- គ្រប់សាលាក្រុង ស្រុក ឃុំ សង្កាត់
- គ្រប់មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត
- គ្រប់រតនាគាររាជធានី ខេត្ត

«ដើម្បីមុខការ»

- ឯកសារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត....................

ឧបសម្ព័ន្ធទី ១

ការគ្រប់គ្រងឆ្នាំ ២០១៤

តារាងសរុបចំណូលថវិការបស់ថ្នាក់រដ្ឋបាល............

ឯកតា: លានរៀល

ជំពូក	គណនី	អនុគណនី	**តារាងរាយមុខចំណូល** (តាមមាតិកាថវិកា)	**ការគ្រប់គ្រងឆ្នាំ ២០១៣**			**គម្រោងឆ្នាំ២០១៤**
				ច្បាប់ហិ.វឆ្នាំ២០១៣	អនុវត្តឆមាសទី១	ប៉ាន់ស្មានឆ្នាំ	

ថ្ងៃទី...........ខែ.................ឆ្នាំ ២០១៣

អ្នកធ្វើតារាង

ថ្ងៃទី...........ខែ.................ឆ្នាំ ២០១៣

ហត្ថលេខា និង ត្រាប្រធានមន្ទីរ

សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ថ្ងៃទី..,.........ខែ.................ឆ្នាំ ២០១៣

ហត្ថលេខា និង ត្រាអភិបាល

នៃគណៈអភិបាលរាជធានី ខេត្ត

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត......................

ការគ្រប់គ្រងឆ្នាំ ២០១៤ **ឧបសម្ព័ន្ធទី ២**

តារាងសរុបចំណាយថវិការបស់ថ្នាក់រដ្ឋបាល.............

ឯកតា: លានរៀល

ជំពូក	គណនី	អនុគណនី	**ការរាយមុខចំណាយ** (តាមមាតិកាថវិកា)	**ការគ្រប់គ្រងឆ្នាំ ២០១៣**			**គម្រោងឆ្នាំ ២០១៤**
				ច្បាប់ហិ.វឆ្នាំ២០១៣	អនុវត្តឆមាសទី១	ប៉ាន់ស្មានឆ្នាំ	

ថ្ងៃទី...........ខែ...........ឆ្នាំ២០១៣

អ្នកធ្វើតារាង

ថ្ងៃទី...........ខែ.................ឆ្នាំ ២០១៣

ហត្ថលេខា និង ត្រាប្រធានមន្ទីរ

សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ថ្ងៃទី...........ខែ...............ឆ្នាំ ២០១៣

ហត្ថលេខា និង ត្រាអភិបាល

នៃគណៈអភិបាលរាជធានី ខេត្ត

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត................ ....

ក្រុង ស្រុក ខណ្ឌ.................

ឧបសម្ព័ន្ធទី ១

ការគ្រប់គ្រងឆ្នាំ ២០១៤

តារាងសរុបចំណូលថវិការបស់ថ្នាក់រដ្ឋបាល............

ឯកតា: លានរៀល

ជំពូក	គណនី	អនុគណនី	**តារាងវាយមុខចំណូល** (តាមមាតិកាថវិកា)	**ការគ្រប់គ្រងឆ្នាំ ២០១៣**			**គម្រោងឆ្នាំ២០១៤**
				ច្បាប់ហិ.វឆ្នាំ២០១៣	អនុវត្តឆមាសទី១	ប៉ាន់ស្មានឆ្នាំ	

ថ្ងៃទី...........ខែ.................ឆ្នាំ ២០១៣

អ្នកធ្វើតារាង

ថ្ងៃទី...........ខែ.................ឆ្នាំ ២០១៣

ហត្ថលេខា និង ត្រាប្រធានមន្ទីរ

សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ថ្ងៃទី...........ខែ.................ឆ្នាំ ២០១៣

ហត្ថលេខា និង ត្រាអភិបាល

នៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត..................

ក្រុង ស្រុក ខណ្ឌ............

ការគ្រប់គ្រងឆ្នាំ ២០១៤

ឧបសម្ព័ន្ធទី ២

តារាងសរុបចំណាយថវិការបស់ថ្នាក់រដ្ឋបាល.............

ឯកតា: លានរៀល

ជំពូក	គណនី	អនុគណនី	**ការរាយមុខចំណាយ** (តាមមាតិកាថវិកា)	**ការគ្រប់គ្រងឆ្នាំ ២០១៣**			**គម្រោងឆ្នាំ ២០១៤**
				ច្បាប់ហិ.វឆ្នាំ២០១៣	អនុវត្តឆមាសទី១	ប៉ាន់ស្មានឆ្នាំ	

ថ្ងៃទី...........ខែ...........ឆ្នាំ២០១៣

អ្នកធ្វើតារាង

ថ្ងៃទី...........ខែ.................ឆ្នាំ ២០១៣

ហត្ថលេខា និង ត្រាប្រធានមន្ទីរ

សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ថ្ងៃទី...........ខែ................ឆ្នាំ ២០១៣

ហត្ថលេខា និង ត្រាអភិបាល

នៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត............ .....

ក្រុង ស្រុក ខណ្ឌ................

ឃុំ សង្កាត់.........................

ការគ្រប់គ្រងឆ្នាំ ២០១៤

ឧបសម្ព័ន្ធទី ១

តារាងសរុបចំណូលថវិការបស់ថ្នាក់រដ្ឋបាល............

ឯកតា: លានរៀល

ជំពូក	គណនី	អនុគណនី	**តារាងរាយមុខចំណូល** (តាមមាតិកាថវិកា)	**ការគ្រប់គ្រងឆ្នាំ ២០១៣**			**គម្រោងឆ្នាំ២០១៤**
				ច្បាប់ហិ.វឆ្នាំ២០១៣	អនុវត្តឆមាសទី១	ប៉ាន់ស្មានឆ្នាំ	

ថ្ងៃទី...........ខែ.................ឆ្នាំ២០១៣

អ្នកធ្វើតារាង

ថ្ងៃទី...........ខែ.................ឆ្នាំ២០១៣

ថ្ងៃទី...........ខែ.................ឆ្នាំ២០១៣

ហត្ថលេខា និង ត្រាប្រធានមន្ទីរ

សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា និង ត្រាអភិបាល

នៃគណៈអភិបាល/ មេឃុំ ចៅសង្កាត់

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត..................

ក្រុង ស្រុក ខណ្ឌ..........

ឃុំ សង្កាត់..................

ការគ្រប់គ្រងឆ្នាំ ២០១៤

ឧបសម្ព័ន្ធទី ២

តារាងសរុបចំណាយថវិការបស់ថ្នាក់រដ្ឋបាល............

ឯកតា: លានរៀល

ជំពូក	គណនី	អនុគណនី	ការរាយមុខចំណាយ (តាមមាតិកាថវិកា)	ការគ្រប់គ្រងឆ្នាំ ២០១៣			គម្រោងឆ្នាំ ២០១៤
				ច្បាប់ហិ.វឆ្នាំ២០១៣	អនុវត្តឆមាសទី១	ប៉ាន់ស្មានឆ្នាំ	

ថ្ងៃទី..........ខែ...........ឆ្នាំ២០១៣

អ្នកធ្វើតារាង

ថ្ងៃទី..........ខែ................ឆ្នាំ ២០១៣

ហត្ថលេខា និង ត្រាប្រធានមន្ទីរ

សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ថ្ងៃទី...........ខែ...............ឆ្នាំ ២០១៣

ហត្ថលេខា និង ត្រាអភិបាល

នៃគណៈអភិបាល/មេឃុំ ចៅសង្កាត់

រាជធានីភ្នំពេញ

ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី១.ក.

គម្រោងថវិកាឆ្នាំ ២០១៤

តារាងសរុបចំណូលថវិការបស់ថ្នាក់រដ្ឋបាលរាជធានីភ្នំពេញ

ឯកតា : លានរៀល

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណូល (តាមតារាងមាតិកាថវិកា)	សរុបរួម	រាជធានី	សរុបខណ្ឌ	សរុបសង្កាត់
			1	2=3+4+5	3	4	5

ថ្ងៃទី............ខែ...... ....ឆ្នាំ២០១៣
អ្នកធ្វើតារាង

ថ្ងៃទី.............ខែ..............ឆ្នាំ ២០១៣
មន្ត្រីលេខា និង គ្រាប្រធានមន្ទីរ
សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី.............ខែ.. ....ឆ្នាំ ២០១៣
បានឃើញ និង ឯកភាព
មន្ត្រីលេខា និង គ្រាអភិបាល
នៃគណៈអភិបាលរាជធានីភ្នំពេញ

៧ ៤ែ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត............

ឧបសម្ព័ន្ធទី១.ខ.

គម្រោងថវិកាឆ្នាំ ២០១៤

តារាងសរុបចំណូលថវិការបស់ថ្នាក់រដ្ឋបាលខេត្ត.........

ឯកតា · លានរៀល

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណូល (តាមតារាងមាតិកាថវិកា)	សរុបរួម	សាលាខេត្ត	ក្រុង			សរុបស្រុក	សរុបឃុំ
						សរុប	សាលាក្រុង	សង្កាត់		
			1	2=3+4+7+8	3	4=5+6	5	6	7	8

ថ្ងៃទី............ខែ...........ឆ្នាំ២០១៣
អ្នកធ្វើតារាង

ថ្ងៃទី.............ខែ..............ឆ្នាំ ២០១៣
ហត្ថលេខា និង ត្រាប្រធានមន្ទីរ
សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី.........ខែ...............ឆ្នាំ ២០១៣
បានឃើញ និង ឯកភាព
ហត្ថលេខា និង ត្រាអភិបាល
នៃគណៈអភិបាល.........

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
ឧបសម្ព័ន្ធទី១.គ.

ខេត្ត............
ក្រុង...............

គម្រោងថវិកាឆ្នាំ ២០១៤

តារាងសរុបចំណូលថវិការបស់ថ្នាក់រដ្ឋបាលក្រុង............

ឯកតា: លានរៀល

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណូល (តាមតារាងមាតិកាថវិកា)	សរុបរួម	សាលាក្រុង	សរុបសង្កាត់	សង្កាត់......	សង្កាត់......	សង្កាត់......	សង្កាត់......	សង្កាត់......	សង្កាត់.	សង្កាត់	. . . .
			1	2=3+4	3	4=5+6+7+....	5	6	7	8	9	10	11	.

ថ្ងៃទី.............ខែ.. .. . ឆ្នាំ២០១៣
អ្នកធ្វើតារាង

ថ្ងៃទី.............ខែ..............ឆ្នាំ២០១៣
ហត្ថលេខា និង ត្រាប្រធានទីចាត់ការ
សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី.. ....ខែ. ....ឆ្នាំ២០១៣
បានឃើញ និង ឯកភាព
ហត្ថលេខា និង ត្រាអភិបាល
នៃគណៈអភិបាលថ្នាក់រដ្ឋបាល..........

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
ឧបសម្ព័ន្ធទី២-ក-

រាជធានីភ្នំពេញ

ឧ

គម្រោងថវិកាឆ្នាំ ២០១៤

តារាងសរុបចំណាយថវិការបស់ថ្នាក់រដ្ឋបាលរាជធានីភ្នំពេញ

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា)	ការគ្រប់គ្រងឆ្នាំ ២០១៤			
				សរុបរួម	រាជធានី	សរុប ខណ្ឌ	សរុបសង្កាត់
			1	2=3+4+5	3	4	5

ថ្ងៃទី.......ខែ...........ឆ្នាំ២០
អ្នកធ្វើតារាង

ថ្ងៃទី...........ខែ............ឆ្នាំ២០១៣
ហត្ថលេខា និងត្រាប្រធានមន្ទីរ
សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ថ្ងៃទី..........ខែ.........ឆ្នាំ២០១៣
បានឃើញ និង ឯកភាព
ហត្ថលេខា និង ត្រាអភិបាល
នៃគណៈអភិបាលរាជធានីភ្នំពេញ

ឧ១

ខេត្ត.............

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
ឧបសម្ព័ន្ធទី២-ខ-

គម្រោងថវិកាឆ្នាំ ២០១៤

តារាងសរុបចំណាយថវិការបស់ថ្នាក់រដ្ឋបាលខេត្ត............

(ឯកតា: លានរៀល)

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា)	ការគ្រប់គ្រងឆ្នាំ ២០១៤						
				សរុបរួម	សាលាខេត្ត	ក្រុង			សរុបស្រុក	សរុបឃុំ
						សរុប	សាលាក្រុង	សង្កាត់		
			1	2=3+4+7+8	3	4=5+6	5	6	7	8

ថ្ងៃទី........ខែ..........ឆ្នាំ២០១៣
បានឃើញ និង ឯកភាព
ហត្ថលេខា និង ត្រាអភិបាល
នៃគណៈអភិបាលថ្នាក់រដ្ឋបាល.........

ថ្ងៃទី..........ខែ...........ឆ្នាំ២០១៣
ហត្ថលេខា និងត្រាប្រធានមន្ទីរ
សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ថ្ងៃទី.........ខែ..........ឆ្នាំ២០១៣
អ្នកធ្វើតារាង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ឧបសម្ព័ន្ធទី២.ត.

ខេត្ត............
ក្រុង.............

គម្រោងថវិកាឆ្នាំ ២០១៤

តារាងសរុបចំណាយថវិការបស់ថ្នាក់រដ្ឋបាលក្រុង............

ឯកតា: លានរៀល

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា)	សរុបរួម	សាលាក្រុង	សរុបសង្កាត់	សង្កាត់......	សង្កាត់......	សង្កាត់......	សង្កាត់......	សង្កាត់......	សង្កាត់......	សង្កាត់......	....
			1	2=3+4	3	4=5+6+7+8+...	5	6	7	8	9	10	11	

ថ្ងៃទី............ខែ.............ឆ្នាំ២០១៣
អ្នកធ្វើតារាង

ថ្ងៃទី............ខែ.............ឆ្នាំ២០១៣
ហត្ថលេខា និង ត្រាប្រធានមន្ទីរ
សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី............ខែ.............ឆ្នាំ២០១៣
បានឃើញ និង ឯកភាព
ហត្ថលេខា និង ត្រាអភិបាល
នៃគណៈអភិបាលថ្នាក់រដ្ឋបាល..........

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត............

ក្រុង ស្រុក..............

ឃុំ សង្កាត់............

គម្រោងថវិកាឆ្នាំ ២០១៤

ជំពូក ៦៤ គម្រោងចំណាយលើបន្ទុកបុគ្គលិកថ្នាក់រដ្ឋបាល ....)

តារាងទី១

ឯកតា: លានរៀល

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា)	សរុបមូលដ្ឋានគិតចំណាយ (មកដល់បច្ចុប្បន្ន)		ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៣			គំរោងថវិកាឆ្នាំ ២០១៤		
				មូលដ្ឋានគិត	បរិមាណ	មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា)	សរុបមូលដ្ឋានគិតចំណាយ	ទឹកប្រាក់ (លានរៀល)	មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា)	សរុបមូលដ្ឋានគិតចំណាយ	ទឹកប្រាក់ (លានរៀល)

ថ្ងៃទី............ខែ..............ឆ្នាំ២០១៣

អ្នកធ្វើតារាង

ថ្ងៃទី............ខែ..............ឆ្នាំ២០១៣

ហត្ថលេខា និង ត្រាប្រធានមន្ទីរ

សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី............ខែ..............ឆ្នាំ២០១៣

បានឃើញ និង ឯកភាព

ហត្ថលេខា និង ត្រាអភិបាល

នៃគណៈអភិបាល...............

p

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត ...
ក្រុង ស្រុក ខណ្ឌ

ការគ្រប់គ្រង ឆ្នាំ២០១៤

តារាងសរុបបុគ្គលិក ប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សាំរដ្ឋបាល......

តារាងទី "ក"

អង្គភាព	សរុប ចំនួន	សរុប បៀវត្ស	ប្រភេទបុគ្គលិកអចិន្ត្រៃយ៍										ក្រុមប្រឹក្សា		បុគ្គលិកអណ្តែត		មន្ត្រីជាប់កិច្ចសន្យា	
			សរុបបុគ្គលិកអចិន្ត្រៃយ៍		ប្រភេទ-ក-		ប្រភេទ-ខ-		ប្រភេទ-គ-		ប្រភេទ-ឃ-							
			ចំនួន	ទឹកប្រាក់	ចំនួន	ទឹកប្រាក់	ចំនួន	ទឹកប្រាក់	ចំនួន	ទឹកប្រាក់	ចំនួន	ទឹកប្រាក់	ចំនួន	ទឹកប្រាក់	ចំនួន	ទឹកប្រាក់	ចំនួន	ទឹកប្រាក់
1	2=4+14+16+18	3=5+15+17+19	4=6+8+10+12	5=7+9+11+13	6	7	8	9	10	11	12	13	14	15	16	17	18	19
សរុប																		
សាលារាជធានី ខេត្ត																		
ក្រុង ស្រុក ខណ្ឌ																		
....																		
....																		
....																		
....																		
....																		
....																		
....																		
....																		

ថ្ងៃទី....... ខែ .... ឆ្នាំ២០១៣

អ្នកធ្វើតារាង

ថ្ងៃទី.............ខែ.............ឆ្នាំ២០១៣

បានឃើញ និង ឯកភាព

ហត្ថលេខា និង ត្រាអភិបាល

នៃគណៈអភិបាលរាជធានី ខេត្ត

ថ្ងៃទី..........ខែ.............ឆ្នាំ២០១៣

ហត្ថលេខា និង ត្រាប្រធានមន្ទីរ

សេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត............

ក្រុង ស្រុក..............

ឃុំ សង្កាត់............

គម្រោងថវិកាឆ្នាំ ២០១៤

(ជំពូក៦២ គម្រោងចំណាយលើសេវាក្រៅផ្សេងៗថ្នាក់រដ្ឋបាល ....) តារាង២

ឯកតា: លានរៀល

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា)	សរុបមូលដ្ឋានគិតចំណាយ (មកដល់បច្ចុប្បន្ន)		ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៣			គំរោងថវិកាឆ្នាំ ២០១៤		
				មូលដ្ឋានគិត	បរិមាណ	មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា)	សរុបមូលដ្ឋានគិតចំណាយ	ទឹកប្រាក់ (លានរៀល)	មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា)	សរុបមូលដ្ឋានគិតចំណាយ	ទឹកប្រាក់ (លានរៀល)

ថ្ងៃទី.............ខែ............ឆ្នាំ២០១៣

អ្នកធ្វើតារាង

ថ្ងៃទី.............ខែ..............ឆ្នាំ២០១៣

ហត្ថលេខា និង ត្រាប្រធានមន្ទីរ

សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី.............ខែ..............ឆ្នាំ២០១៣

បានឃើញ និង ឯកភាព

ហត្ថលេខា និង ត្រាអភិបាល

នៃគណៈអភិបាល..........

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត ....
ក្រុង ស្រុក.................
ឃុំ សង្កាត់............

គម្រោងថវិកាឆ្នាំ ២០១៤

(ជំពូក៦០ គម្រោងចំណាយលើការទិញ ថ្នាក់រដ្ឋបាល............) តារាងទី៣

ឯកតា: លានរៀល

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា)	សរុបមូលដ្ឋានគិតចំណាយ (មានលំអិតបន្ថែម)		ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៣			គំរោងថវិកាឆ្នាំ ២០១៤		
				មូលដ្ឋានគិត	បរិមាណ	មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា)	សរុបមូលដ្ឋានគិតចំណាយ	ទឹកប្រាក់ (លានរៀល)	មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា)	សរុបមូលដ្ឋានគិតចំណាយ	ទឹកប្រាក់ (លានរៀល)

ថ្ងៃទី............ខែ..............ឆ្នាំ២០១៣
អ្នកធ្វើតារាង

ថ្ងៃទី............ខែ..............ឆ្នាំ២០១៣
ហត្ថលេខា និង ត្រាប្រធានមន្ទីរ
សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី............ខែ..............ឆ្នាំ២០១៣
បានឃើញ និង ឯកភាព
ហត្ថលេខា និង ត្រាអភិបាល
នៃគណៈអភិបាល ....

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត............

ក្រុង ស្រុក...............

ឃុំ សង្កាត់............

គម្រោងថវិកាឆ្នាំ ២០១៤ គម្រោងចំណាយលើសេវាខាងក្រៅ

(ជំពូក ៦១ គុណប្រយោជន៍ថ្នាក់រដ្ឋបាល...............)

តារាងទី៤

ឯកតា: លានរៀល

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា)	សរុបមូលដ្ឋានគិតចំណាយ (មកពីលម្អិតបុគ្គល)		ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៣			គំរោងថវិកាឆ្នាំ ២០១៤		
				មូលដ្ឋានគិត	បរិមាណ	មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនាមួយឯកតា)	សរុបមូលដ្ឋានគិតចំណាយ	ទឹកប្រាក់ (លានរៀល)	មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនាមួយឯកតា)	សរុបមូលដ្ឋានគិតចំណាយ	ទឹកប្រាក់ (លានរៀល)

ថ្ងៃទី............ខែ..............ឆ្នាំ២០១៣

អ្នកធ្វើតារាង

ថ្ងៃទី............ខែ..............ឆ្នាំ២០១៣

ហត្ថលេខា និង ត្រាប្រធានមន្ទីរ

សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី............ខែ..............ឆ្នាំ២០១៣

បានឃើញ និង ឯកភាព

ហត្ថលេខា និង ត្រាអភិបាល

នៃគណៈអភិបាល...............

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត............

ក្រុង ស្រុក...............

ឃុំ សង្កាត់...........

គម្រោងថវិកាឆ្នាំ ២០១៤

(ជំពូក ៦៥ គម្រោងចំណាយលើឧបត្ថម្ភកធន និងជំនួយសង្គមថ្នាក់រដ្ឋបាល..........) តារាងទី៥

ឯកតា: លានរៀល

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា)	សរុបមូលដ្ឋានគិតចំណាយ (មកដល់បច្ចុប្បន្ន)		ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៣			គំរោងថវិកាឆ្នាំ ២០១៤		
				មូលដ្ឋានគិត	បរិមាណ	មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា)	សរុបមូលដ្ឋានគិតចំណាយ	ទឹកប្រាក់ (លានរៀល)	មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា)	សរុបមូលដ្ឋានគិតចំណាយ	ទឹកប្រាក់ (លានរៀល)

ថ្ងៃទី............ខែ.............ឆ្នាំ២០១៣

អ្នកធ្វើតារាង

ថ្ងៃទី............ខែ.............ឆ្នាំ២០១៣

ហត្ថលេខា និង ត្រាប្រធានមន្ទីរ

សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី............ខែ..............ឆ្នាំ២០១៣

បានឃើញ និង ឯកភាព

ហត្ថលេខា និង ត្រាអភិបាល

នៃគណៈអភិបាល...........

p

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្ត...........

ក្រុង ស្រុក...............

ឃុំ សង្កាត់............

គម្រោងថវិកាឆ្នាំ ២០១៤

(ជំពូក ៦៣ គម្រោងចំណាយលើពន្ធ និង អាករថ្នាក់រដ្ឋបាល............) តារាងទី៦

ឯកតា: លានរៀល

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ (តាមតារាងមាតិកាថវិកា)	សរុបមូលដ្ឋានគិតចំណាយ (មានលំអិតឧបសម្ព័ន្ធ)		ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៣			គំរោងថវិកាឆ្នាំ ២០១៤		
				មូលដ្ឋានគិត	បរិមាណ	មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា)	សរុបមូលដ្ឋានគិតចំណាយ	ទឹកប្រាក់ (លានរៀល)	មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា)	សរុបមូលដ្ឋានគិតចំណាយ	ទឹកប្រាក់ (លានរៀល)

ថ្ងៃទី............ខែ.............ឆ្នាំ២០១៣

អ្នកធ្វើតារាង

ថ្ងៃទី............ខែ.............ឆ្នាំ២០១៣

ហត្ថលេខា និង ត្រាប្រធានមន្ទីរ

សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី............ខែ.............ឆ្នាំ២០១៣

បានឃើញ និង ឯកភាព

ហត្ថលេខា និង ត្រាអភិបាល

នៃគណៈអភិបាល.................

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង............

ក្រុង ស្រុក...........

ឃុំ សង្កាត់..........

គម្រោងថវិកាឆ្នាំ ២០១៤

(ជំពូក ២០និង២១ អចលកម្មអរូបីយ៍ និងអចលកម្មរូបីយ៍ ថ្នាក់រដ្ឋបាល..........) តារាងទី៧

ឯកតា: លានរៀល

ជំពូក	គណនី	អនុគណនី	ចំណាត់ថ្នាក់ចំណាយ (តាមការងារមាតិកាថវិកា)	សរុបមូលដ្ឋានគិតចំណាយ (មានដល់បច្ចុប្បន្ន)		ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៣			គំរោងថវិកាឆ្នាំ ២០១៤		
				មូលដ្ឋានគិត	បរិមាណ	មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា)	សរុបមូលដ្ឋានគិតចំណាយ	ទឹកប្រាក់ (លានរៀល)	មូលដ្ឋានគិតចំណាយ (ដោយបង្ហាញការគណនា១ឯកតា)	សរុបមូលដ្ឋានគិតចំណាយ	ទឹកប្រាក់ (លានរៀល)

ថ្ងៃទី..............ខែ...............ឆ្នាំ២០១៣

អ្នកធ្វើតារាង

ថ្ងៃទី..............ខែ...............ឆ្នាំ២០១៣

ហត្ថលេខា និង ត្រាប្រធានមន្ទីរ

សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ថ្ងៃទី..............ខែ...............ឆ្នាំ២០១៣

បានឃើញ និង ឯកភាព

ហត្ថលេខា និង ត្រាអភិបាល

នៃគណៈអភិបាល..........

p

បោះពុម្ពនៅអគ្គនាយកដ្ឋាន

រាជកិច្ច និង សេវាកុំព្យូទ័រ

នៃ ទីស្ដីការគណៈរដ្ឋមន្ត្រី